# កិច្ចព្រមព្រៀង
# ស្ដីពីដំណោះស្រាយ
# នយោបាយរួមមួយ
# នៃ ជំលោះកម្ពុជា

ថ្ងៃ 23 តុលា 1991

អ៊ុនតាក់

មាតិកា ទំព័រ


I./ - កិច្ចព្រមព្រៀង ស្តីពីដំណោះស្រាយនយោបាយរួម
រួមនៃជំលោះកម្ពុជា ........................................ 3

ឧបសម្ព័ន្ធទី 1

* ការៈកិច្ចរបស់អាជ្ញាធរបណ្តោះអាសន្ន អ.ស.ប
នៅកម្ពុជា " អ៊ុនតាក់ " ........................................ 13

ឧបសម្ព័ន្ធទី 2

* ការដកកងកំលាំង ការឈប់បាញ់ និង វិធានការណ៍
ពាក់ព័ន្ធ ........................................ 19

ឧបសម្ព័ន្ធទី 3

* ការបោះឆ្នោត ........................................ 28

ឧបសម្ព័ន្ធទី 4

* ការធ្វើមាតុភូមិនិវត្តន៍ជនភៀសខ្លួន និងជនផ្លាស់ប្តូរ
ទីកន្លែងកម្ពុជា ........................................ 30

ឧបសម្ព័ន្ធទី ៥

* បណ្តាគោលការណ៍សំរាប់រដ្ឋធម្មនុញ្ញថ្មី
របស់កម្ពុជា ........................................ 33

II./ - កិច្ចព្រមព្រៀងទាក់ទិននឹងអធិបតេយ្យភាព
ឯករាជ្យ បូរណភាព និងភាពមិនអាចរំលោភ
បាននៃដែនដី អព្យាក្រឹតភាព ឯកភាពជាតិកម្ពុជា ........................................ 34

III./ - សេចក្តីថ្លែងការណ៍ ស្តីពីការស្តារ និង ការ
កសាងប្រទេសកម្ពុជាឡើងវិញ ........................................ 39

កិច្ចព្រមព្រៀងចុងក្រោយនៃសន្និសីទប៉ារីស
ស្តីពីកម្ពុជា ........................................ 41

# I. កិច្ចព្រមព្រៀងស្ដីពីដំណោះស្រាយនយោបាយរួមមួយនៃជំលោះកម្ពុជា

បណ្ដារដ្ឋដែលបានចូលរួមក្នុងសន្និសីទទីក្រុងប៉ារីសស្ដីពីកម្ពុជា គឺអូស្ត្រាលី ប្រ៊ុយណេ ដារូសាឡឹម -កម្ពុជា-កាណាដា-សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋបារាំង-សាធារណរដ្ឋឥណ្ឌា-សាធារណរដ្ឋឥណ្ឌូណេស៊ី-ជប៉ុន-សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ-ម៉ាឡេស៊ី- សាធារណរដ្ឋហ្វីលីពីន- សាធារណរដ្ឋសិង្ហបុរី- រាជាណាចក្រថៃឡង់- សហភាពសាធារណរដ្ឋសង្គមនិយមសូវៀត - រាជាណាចក្ររួមនៃគ្រេតប្រ៊ីតាញនិងអៀរឡង់ខាងជើង-សហរដ្ឋអាមេរិក-សាធារណរដ្ឋសង្គមនិយមវៀតណាម និងសាធារណរដ្ឋសហព័ន្ធសង្គមនិយមយូហ្គោស្លាវី ។

នៅចំពោះវត្តមាននៃលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ

ដើម្បីថែរក្សា និងការពារអធិបតេយ្យភាព-ឯករាជ្យ បូរណភាពនិងភាពមិនរំលោភបានលើទឹកដី អព្យាក្រឹត- ភាព និងឯកភាពជាតិរបស់កម្ពុជា

ដោយចង់ ស្ដារឡើងវិញ និងថែរក្សាសន្តិភាពនៅកម្ពុជា ជំរុញការបង្រួបបង្រួមជាតិនិងធានាអោយប្រជាជនកម្ពុជាប្រើប្រាស់សិទ្ធិស្វ័យសំរេចតាមរយៈការបោះឆ្នោតដោយសេរី និងត្រឹមត្រូវ

ដោយជឿជាក់ថា មានតែដំណោះស្រាយនយោបាយរួមមួយសំរាប់ជំលោះកម្ពុជាទេ ទើបបានជាដំណោះស្រាយយុត្តិធម៌ និងយូរអង្វែង ហើយនិងរួមវិភាគទានដល់សន្តិភាព និងសន្តិសុខក្នុងតំបន់និងអន្តរជាតិ

ដោយស្វាគមន៍ ឯកសារក្របខ័ណ្ឌ ថ្ងៃទី ២៨ សីហា ១៩៩០ ដែលបានព្រមព្រៀងទាំងស្រុងដោយភាគីកម្ពុជាធ្វើជាមូលដ្ឋានសំរាប់ដោះស្រាយនៃជំលោះកម្ពុជា ហើយនោះដែរ ត្រូវបានយល់ព្រមជាឯកច្ឆ័ន្ទដោយក្រុមប្រឹក្សាសន្តិសុខតាមសេចក្ដីសំរេចចិត្តលេខ ៦៦៨ ១៩៩០ ចុះថ្ងៃទី ២០ កញ្ញា ១៩៩០ និងដោយមហាសន្និបាត អ.ស.ប តាមសេចក្ដីសំរេចចិត្តលេខ ៤៥.៣ ចុះថ្ងៃទី ១៥ តុលា ១៩៩០ ។

ដោយកត់សំគាល់ ការបង្កើតឡើងនូវក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជា នៅហ្សាការតា ថ្ងៃទី ១០ កញ្ញា ១៩៩០ ជាអង្គការស្ថាប័នស្របច្បាប់និងជាប្រភពអំណាចតែមួយគត់នៅកម្ពុជា ដែលនៅក្នុងទូទាំងដំណាក់កាល អន្តរកាល ជាតំណាងតំកល់ អធិបតេយ្យភាព និងឯកភាពជាតិ ហើយដែលតំណាងកម្ពុជានៅបរទេស ។

ដោយស្វាគមន៍ ការជ្រើសតាំងជាឯកច្ឆ័ន្ទនូវសម្ដេចនរោត្តម សីហនុ ជាប្រធានក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៅប៉េកាំង ថ្ងៃទី ១៧ កក្កដា ១៩៩១

ដោយទទួលស្គាល់ថា តួនាទីដ៏ចាំបាច់របស់អង្គការសហប្រជាជាតិ ទាមទារឲ្យបង្កើតអាជ្ញាធរបណ្ដោះអាសន្នរបស់អង្គការសហប្រជាជាតិមួយនៅកម្ពុជា " អ៊ុនតាក់ " ដោយមានផ្នែកយោធានិង ផ្នែកស៊ីវិល ដែលនឹងបំពេញការកិច្ចដោយគោរពទាំងស្រុងដល់អធិបតេយ្យភាពជាតិរបស់កម្ពុជា

ដោយកត់សំគាល់ នូវសេចក្ដីថ្លែងការណ៍នៅពេលបញ្ចប់កិច្ចប្រជុំដែលបានប្រព្រឹត្តទៅនៅហ្សាកាតា ថ្ងៃ ៩-១០ កញ្ញា ១៩៩០ នៅប៉ារីស ថ្ងៃទី ២១-២៣ ធ្នូ ១៩៩០ នៅប៉ាតាយ៉ា ថ្ងៃទី ២៤-២៦ មិថុនា ១៩៩១ នៅប៉េកាំងថ្ងៃទី ១៦-១៧ កក្កដា ១៩៩១ នៅប៉ាតាយ៉ា ថ្ងៃទី ២៦-២៩ សីហា ១៩៩១ ព្រមទាំង កិច្ចប្រជុំនៅហ្សាកាតា ថ្ងៃទី៤-៦ មិថុនា ១៩៩១ និង នៅញូវយ៉ក ថ្ងៃទី ១៩ កញ្ញា ១៩៩១

ដោយស្វាគមន៍ សេចក្ដីសំរេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ៧១៧ "១៩៩១" ចុះថ្ងៃទី ១៦ តុលា ១៩៩១ ស្ដីពីកម្ពុជា

ដោយទទួលស្គាល់ថា ប្រវត្តិសាស្ត្រថ្មីៗ ប្រកបដោយសោកនាដកម្មរបស់កម្ពុជា ទាមទារឲ្យមានវិធានការពិសេស ដើម្បីធានាការពារ សិទ្ធិមនុស្ស និងការមិនវិលត្រឡប់មកវិញនៃនយោបាយនិងអំពើប្រព្រឹត្តិពីអតីតកាល

បានព្រមព្រៀងដូចតទៅនេះ :

# ភាគទី ១

## ការរៀបចំក្នុងដំណាក់កាលអន្តរកាល

## ផ្នែកទី ១

## ដំណាក់កាលអន្តរកាល

### មាត្រាទី ១

ដើម្បីបំរើវត្ថុបំណងនៃកិច្ចព្រមព្រៀងនេះ ដំណាក់អន្តរកាលត្រូវចាប់ផ្ដើមពីពេលដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន ហើយត្រូវបញ្ចប់នៅពេលដែលសភាធម្មនុញ្ញដែលបានជាប់ឆ្នោតតាមរយៈនៃការបោះឆ្នោតដោយសេរី និងត្រឹម ត្រូវ ដែលរៀបចំឡើងនិងបញ្ជាក់ដោយអង្គការសហប្រជាជាតិ បានអនុម័តរដ្ឋធម្មនុញ្ញ ហើយបានក្លាយខ្លួនឯងទៅជាសភានីតិបញ្ញត្តិ រួចបន្ទាប់មករដ្ឋាភិបាលថ្មីមួយត្រូវបានបង្កើតឡើង ។

## ផ្នែកទី ២

## អាជ្ញាធរបណ្ដោះអាសន្ននៃ អ.ស.ប នៅកម្ពុជា

## មាត្រា ២

១-ហត្ថលេខីទាំងឡាយស្នើក្រុមប្រឹក្សាសន្តិសុខ អ.ស.ប អោយបង្កើត អាជ្ញាធរបណ្តោះអាសន្ននៃ អ.ស.ប មួយនៅកម្ពុជា (ចាប់ពីពេលនេះទៅហៅថាអ៊ុនតាក់ "UNTAC") ដោយរួមមានទាំងផ្នែកយោធានិងផ្នែកស៊ីវិល ដែលស្ថិតនៅក្រោមការទទួលខុសត្រូវផ្ទាល់របស់អគ្គលេខាធិការនៃអ.ស.ប ។ ដើម្បីសំរេចគោលបំណងនេះ លោកអគ្គលេខាធិការនៃអ.ស.ប ត្រូវចាត់តាំងតំណាងពិសេសម្នាក់អោយបំពេញការកិច្ចក្នុងនាមរបស់លោក ។

២-ហត្ថលេខីទាំងឡាយក៏ស្នើថែមទៀតដល់ក្រុមប្រឹក្សាសន្តិសុខ អ.ស.ប អោយប្រគល់ដល់អ៊ុនតាក់ "UNTAC" នូវតួនាទីការកិច្ចមួយដូចដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ ហើយត្រូវពិនិត្យការអនុវត្តន៍ការកិច្ចនេះអោយបានជាប់ហូរហែ តាមរយៈរបាយការណ៍ទៀងទាត់ធ្វើដោយលោកអគ្គលេខាធិការ ។

## ផ្នែកទី ៣

## ក្រុមប្រឹក្សាជាតិជាន់ខ្ពស់

### មាត្រា ៣

ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ (ចាប់ពីពេលនេះទៅហៅថា "អេសអិនស៊ី SNC") ជាអង្គការ ស្របច្បាប់និងជាប្រភពនៃអំណាចតែមួយគត់ ដែលតំណាងតំកល់អធិបតេយ្យភាព-ឯករាជ្យ និងឯកភាពនៃកម្ពុជាក្នុងដំណាក់កាលអន្តរកាល ។

### មាត្រា ៤

បណ្តាសមាជិក អេសអិនស៊ី "SNC" និងត្រូវសន្យាអោយមានការចាត់តាំងការបោះឆ្នោតដោយសេរី និងត្រឹមត្រូវ រៀបចំឡើងនិងដឹកនាំដោយសហប្រជាជាតិ ធ្វើជាមូលដ្ឋានសំរាប់រៀបចំរដ្ឋាភិបាលថ្មីនិងស្របច្បាប់មួយ ។

### មាត្រា ៥

នៅក្នុងទូទាំងដំណាក់កាលអន្តរកាល អេសអិនស៊ី "SNC" ជាតំណាងកម្ពុជានៅក្រៅប្រទេស ហើយត្រូវ កាន់កាប់អាសនៈកម្ពុជានៅអ.ស.ប នៅអង្គការជំនាញទាំងឡាយរបស់អ.ស.ប និងនៅក្នុងស្ថាប័នអន្តរជាតិ និងនៅក្នុងបណ្តាសន្និសីទអន្តរជាតិផ្សេងៗទៀត ។

### មាត្រា ៦

អាស្រ័យហេតុនេះ អេសអិនស៊ី ប្រគល់អំណាចទាំងអស់ដែលចាំបាច់អោយអ៊ុនតាក់ ដើម្បីធានាការអនុវត្តន៍កិច្ចព្រមព្រៀងនេះ ដូចមានពិពណ៌នានៅក្នុងឧបសម្ព័ន្ធទី ១ ស្រាប់ ។

ដើម្បីធានាបរិយាកាសនយោបាយអព្យាក្រឹតមួយ សម្រួលដល់ការបោះឆ្នោតទូទៅដោយសេរីនិងត្រឹមត្រូវ គេត្រូវដាក់បណ្ដាភ្នាក់ងារ ស្ថាប័ន និងការិយាល័យរដ្ឋ ដែលអាចមានឥទ្ធិពលដោយផ្ទាល់ទៅលើលទ្ធផលនៃការបោះឆ្នោតអោយស្ថិតនៅក្រោមការពិនិត្យមើលឬត្រួតពិនិត្យដោយផ្ទាល់របស់អង្គការសហប្រជាជាតិ ។ ក្នុងក្របខ័ណ្ឌនេះ គេត្រូវចាប់អារម្មណ៍ពិសេសទៅលើកិច្ចការងារការបរទេស ការពារប្រទេស ហិរញ្ញវត្ថុ សន្តិសុខសាធារណៈ និងឃោសនាការ។ ដើម្បីឆ្លុះបញ្ចាំងអោយឃើញសារៈសំខាន់នៃបញ្ហានេះ អ៊ុនតាក់ " UNTAC " ចាំបាច់ត្រូវធ្វើការត្រួតពិនិត្យតាមដែលចាំបាច់ ដើម្បីធានាអព្យាក្រឹតភាពដ៏ម៉ឺងម៉ាត់នៃបណ្ដាស្ថាប័ន ដែលទទួលខុសត្រូវលើវិស័យទាំងនេះ ។ អង្គការសហប្រជាជាតិដោយមានការពិគ្រោះជាមួយ អេស អិន ស៊ី "SNC" ត្រូវពិនិត្យកំណត់មើលថា តើភ្នាក់ងារណា ស្ថាប័នណា និង ការិយាល័យណាអាចបំពេញការសកម្មភាពតទៅទៀត ដើម្បីធានាជីវភាពប្រចាំថ្ងៃធម្មតានៅក្នុងប្រទេស ។

## មាត្រាទី ៧

ទំនាក់ទំនងរវាង អេស អិន ស៊ី "SNC" និងអ៊ុនតាក់ "UNTAC" និងជាមួយបណ្ដាភាគីកម្ពុជា ដែលមានសរសេរនៅក្នុងឧបសម្ព័ន្ធទី ១ ។

## ផ្នែកទី ៣

## ការដកកងកំលាំងបរទេស និងការពិនិត្យបញ្ជាក់

## មាត្រាទី ៨

ពេលកិច្ចព្រមព្រៀងនេះចូលជាធរមានភ្លាម រាល់កងកម្លាំង ទីប្រឹក្សា និងបុគ្គលិកយោធាបរទេសទាំងឡាយណាដែលមាននៅក្នុងប្រទេសកម្ពុជា រួមទាំងសព្វាវុធ គ្រឿងរំសេវ និងសម្ភារៈរបស់គេ ត្រូវដកចេញពីកម្ពុជា និងមិនត្រូវត្រឡប់មកវិញទេ។ ការដក និងការមិនត្រឡប់នេះវិញត្រូវស្ថិតក្រោមការត្រួតពិនិត្យបញ្ជាក់របស់អ៊ុនតាក់ "UNTAC" ស្របតាមឧបសម្ព័ន្ធទី ២ ។

## ផ្នែកទី ៤

## ការឈប់បាញ់គ្នា និងការបញ្ឈប់នូវជំនួយយោធាពីខាងក្រៅ

## មាត្រាទី ៩

ការឈប់បាញ់គ្នាត្រូវចាប់អនុវត្តចាប់តាំងពីពេលដែលកិច្ចព្រមព្រៀងចូលជាធរមាន ។ គ្រប់កងកម្លាំងទាំងអស់ត្រូវ[illegible] ដែលឈប់ប្រឆាំងគ្នា ហើយត្រូវផ្អាកឈប់ធ្វើសកម្មភាពប្រើប្រាស់អាវុធទាំងអស់ និង ឈប់ដាក់ពង្រាយថែមទៀត កសាងកម្លាំង ឬធ្វើសកម្មភាពទាំងឡាយណាដែលនាំអោយពង្រីកដែនដីដែលខ្លួនត្រួតត្រា ឬ ក៏ដែលអាចនាំទៅរកការប្រយុទ្ធគ្នាជាថ្មី ។

ហេតុនេះ បណ្តាហត្ថលេខីស្នើដល់ក្រុមប្រឹក្សាសន្តិសុខ អ.ស.ប ឲ្យស្នើទៅលោកអគ្គលេខាធិការឲ្យជួយឧបត្ថម្ភសំរួលដល់ដំណើរការនេះ រហូតដល់ពេលដែលផ្នែកយោធារបស់អ៊ុនតាក់ "UNTAC" អាចធានាលទ្ធភាពត្រួតពិនិត្យ តាមដាន និងបញ្ជាក់អំពីការដកចេញនេះ ។

## មាត្រាទី ១០

នៅពេលកិច្ចព្រមព្រៀងនេះចូលជាធរមាន ត្រូវបញ្ឈប់ជាបន្ទាន់នូវជំនួយយោធាបរទេសទាំងអស់ទៅឲ្យភាគីកម្ពុជាទាំងអស់ ។

## មាត្រាទី ១១

ទិសដៅនៃការរៀបចំផ្នែកយោធា ក្នុងដំណាក់កាលបណ្តោះអាសន្នគឺត្រូវធ្វើឲ្យស្ថានការណ៍សន្តិសុខមានស្ថិរភាព និងកសាងទំនុកចិត្តរវាងភាគីក្នុងជំលោះ ដើម្បីពង្រឹងគោលបំណងនៃកិច្ចព្រមព្រៀងនេះ និងដើម្បីជៀសវាងគ្រោះថ្នាក់នៃការវិលត្រឡប់ទៅរកសង្គ្រាមវិញ ។

បទបញ្ញត្តិលំអិតស្តីពីការត្រួតពិនិត្យ ការតាមដាន និងបញ្ជាក់អំពីការដកចេញនិងវិធានការពាក់ព័ន្ធ រួមទាំងការបញ្ជាក់អំពីការដកចេញពីបរទេសនិងការប្រមូលផ្តុំ ការដាក់ក្នុងបន្ទាយ និងការរំលាយជាចុងក្រោយនៃកងកម្លាំងកម្ពុជាទាំងអស់ ព្រមទាំងសព្វាវុធរបស់គេទៅក្នុងដំណាក់កាលបណ្តោះអាសន្ន គឺមានចែងនៅក្នុងឧបសម្ព័ន្ធ ១ ជំពូក គ និងឧបសម្ព័ន្ធ ២ ។

# ភាគទី ២

## ការបោះឆ្នោត

## មាត្រាទី ១២

ប្រជាជនកម្ពុជាត្រូវមានសិទ្ធិសំរេចពីអនាគតនយោបាយរបស់ខ្លួនតាមរយៈការបោះឆ្នោតដោយសេរី និងត្រឹមត្រូវ ដើម្បីជ្រើសរើសសភាធម្មនុញ្ញមួយ ដែលត្រូវព្រាងនិងអនុម័តរដ្ឋធម្មនុញ្ញកម្ពុជាមួយថ្មីស្របទៅតាមមាត្រា ២៣ ហើយត្រូវក្លាយខ្លួនទៅជាសភានីតិបញ្ញត្តិ ដែលត្រូវបង្កើតរដ្ឋាភិបាលកម្ពុជាមួយថ្មី ។ ការបោះឆ្នោតនេះធ្វើឡើងក្រោមការឧបត្ថម្ភចាត់ចែងរបស់ អ.ស.ប ក្នុងបរិយាកាសនយោបាយអព្យាក្រឹតមួយ ដោយគោរពយ៉ាងពេញលេញ ដល់អធិបតេយ្យភាពជាតិរបស់កម្ពុជា ។

## មាត្រាទី ១៣

អ៊ុនតាក់ "UNTAC" ត្រូវទទួលខុសត្រូវចំពោះការរៀបចំនិងដឹកនាំការបោះឆ្នោតទាំងនេះ ដោយផ្អែកលើប្រការទាំងឡាយដែលមានចែងក្នុងឧបសម្ព័ន្ធ ១ ជំពូក ឃ និងឧបសម្ព័ន្ធ ៣ ។

## មាត្រាទី ១៤

ហត្ថលេខីទាំងអស់ត្រូវប្តេជ្ញាគោរពលទ្ធផលនៃការបោះឆ្នោតទាំងនេះនៅពេលណាដែលអង្គការសហប្រជាជាតិបាន បញ្ជាក់ថា ការបោះឆ្នោតនោះបានប្រព្រឹត្តទៅដោយសេរី និងត្រឹមត្រូវហើយ ។

# ភាគទី ៣

# សិទ្ធិមនុស្ស

## មាត្រា ១៥

១- មនុស្សគ្រប់រូបនៅក្នុងប្រទេសកម្ពុជា និងជនភៀសខ្លួន និងជនផ្លាស់ប្តូរទីកន្លែងនៅកម្ពុជាទាំងអស់ ត្រូវមានសិទ្ធិ និងសេរីភាព ដែលមានចែងនៅក្នុងសេចក្តីប្រកាសជាសកលពីសិទ្ធិមនុស្ស និងក្នុងបណ្តាកិច្ចព្រមព្រៀងអន្តរជាតិ ទាំងឡាយ ដែលពាក់ព័ន្ធដល់ស្តីពីសិទ្ធិមនុស្ស ។

២- ដើម្បីសំរេចទិសដៅនេះ :

ក- ប្រទេសកម្ពុជាសន្យាថានឹង :

- ធានាគោរព និងប្រតិបត្តិតាមសិទ្ធិមនុស្ស និងសេរីភាព ជាមូលដ្ឋាននៅកម្ពុជា
- គាំទ្រសិទ្ធិរបស់ពលរដ្ឋកម្ពុជាទាំងអស់ក្នុងការធ្វើសកម្មភាពដែលជំរុញនិងការពារសិទ្ធិ មនុស្ស និង សេរីភាពជាមូលដ្ឋាន
- ចាត់បណ្តាវិធានការដ៏ចាំបាច់ដើម្បីធានាថា នយោបាយនិងអំពើប្រព្រឹត្តក្នុង អតីតកាលមិន ត្រូវបានអនុញ្ញាតអោយវិលត្រឡប់មកវិញជាដាច់ខាត
- ចូលរួមកិច្ចព្រមព្រៀងជាអន្តរជាតិទាំងឡាយដែលពាក់ព័ន្ធដល់សិទ្ធិមនុស្ស

ខ- ហត្ថលេខីផ្សេងៗទៀត នៃកិច្ចព្រមព្រៀងនេះសន្យាថាជួយជំរុញនិងលើកទឹកចិត្តដល់ការគោរព និងប្រតិបត្តិតាម សិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាននៅក្នុងកម្ពុជា ដូចដែលមានចែងនៅក្នុង កិច្ចព្រមព្រៀងអន្តរជាតិទាំងឡាយនិង សេចក្តីសំរេចចិត្តទាំងឡាយរបស់មហាសន្និបាត អ.ស.ប ដែលទាក់ទងនឹងបញ្ហានេះ ដើម្បីជាពិសេសការពារទប់ទល់និងការ កកើតឡើងវិញការរំលោភសិទ្ធិមនុស្សជាថ្មីទៀត ។

## មាត្រា ១៦

ក្នុងចំណាក់កាលអន្តរកាល អ៊ុនតាក់ " UNTAC " ត្រូវទទួលខុសត្រូវបង្កើតនូវបរិយាកាសមួយធានាដល់ការ គោរពសិទ្ធិមនុស្ស ដោយផ្អែកលើប្រការដែលមានចែងក្នុងឧបសម្ព័ន្ធទី ១ ជំពូក ង ។

## មាត្រា ១៧

ក្រោយពីរយៈកាលអន្តរកាលត្រូវបានបញ្ចប់ គណៈកម្មការ ស.ប. ស្តីពីសិទ្ធិមនុស្ស គប្បីបន្តតាមដានអោយបានជិតដល់ពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ហើយបើចាំបាច់ គួររួមទាំងការតែងតាំងអ្នកធ្វើកំណត់ហេតុពិសេស ម្នាក់ដែលត្រូវធ្វើរបាយការណ៍ប្រចាំឆ្នាំស្តីពីលទ្ធផលនៃការរកឃើញរបស់ខ្លួន ទៅជូនគណៈកម្មការ និងមហាសន្និបាត ។

# ភាគទី ៤

## ការពារអធិបតេយ្យ

### មាត្រាទី ១៨

កម្ពុជាសន្យាថានឹងថែរក្សា ការពារ ហើយបណ្តាហត្ថលេខីផ្សេងទៀតសន្យាថា ទទួលស្គាល់និងគោរពចំពោះ អធិបតេយ្យភាព ឯករាជ្យ បូរណភាព និងភាពមិនរំលោភបាននៃដែនដី អព្យាក្រឹតភាព និង ឯកភាពជាតិនៃកម្ពុជា ដូចមានចែងក្នុងកិច្ចព្រមព្រៀងមួយដាច់ដោយឡែក ។

# ភាគទី ៥

## ជនភៀសខ្លួន និងជនផ្លាស់ប្តូរទីកន្លែង

### មាត្រាទី ១៩

កាលបើកិច្ចព្រមព្រៀងនេះចូលជាធរមាន គេត្រូវខិតខំប្រឹងប្រែងជាទីបំផុតអោយមានលក្ខណៈសម្បត្តិនយោបាយ សេដ្ឋកិច្ច និងសង្គមនៅក្នុងប្រទេសកម្ពុជា ដែលនាំផ្តល់អោយដល់ការវិលត្រឡប់ដោយស្ម័គ្រចិត្ត និងការចូលមកក្នុងសង្គមជាតិវិញដោយសុខដុមរមនានៃជនភៀសខ្លួន និងជនផ្លាស់ប្តូរទីកន្លែងកម្ពុជា ។

### មាត្រាទី ២០

១- ជនភៀសខ្លួន និងជនផ្លាស់ប្តូរទីកន្លែងកម្ពុជា ដែលរស់នៅក្រៅប្រទេសកម្ពុជា ត្រូវមានសិទ្ធិវិលត្រឡប់មកប្រទេសកម្ពុជាវិញ និងរស់នៅដោយសុវត្ថិភាព សន្តិសុខ និង ភាពថ្លៃថ្នូរ ដោយគ្មានការសំឡុតគំរាមកំហែង ឬការគាបសង្កត់បែបណាមួយឡើយ ។

២- ហត្ថលេខីទាំងឡាយស្នើសុំចំពោះលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ អោយជួយសម្របសម្រួលដល់ការធ្វើមាតុភូមិនិវត្តន៍ នៃជនភៀសខ្លួន និងជនផ្លាស់ប្តូរទីកន្លែងកម្ពុជា អោយប្រកបដោយសុវត្ថិភាព និងភាពថ្លៃថ្នូរ ក្នុងក្របខ័ណ្ឌជាភាគមួយនៃដំណោះស្រាយនយោបាយរួមដែលប្រព្រឹត្តទៅក្រោមអំណាចត្រួតពិនិត្យរបស់តំណាង ពិសេសនៃលោកអគ្គលេខាធិការ

ស្របតាម សេចក្ដីណែនាំ និង គោលការណ៍ស្ដីពីមាតុភូមិនិវត្តន៍នៃជនភៀសខ្លួន និង ជនផ្លាស់ប្ដូរទីកន្លែង ដូចដែលមានចែងនៅក្នុង ឧបសម្ព័ន្ធទី ៤ ។

## ភាគទី ៦

## ការដោះលែងឈ្លើយសឹក និង ជនស៊ីវិលជាប់ឃុំ

### មាត្រាទី ២១

ការដោះលែងឈ្លើយសឹក និង ជនស៊ីវិលជាប់ឃុំឃាំងទាំងអស់ត្រូវសំរេចឡើងក្នុងពេលដ៏ឆាប់រហ័សបំផុត តាមដែលអាចធ្វើទៅបាន ក្រោមការដឹកនាំរបស់គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ " CICR " ដោយមានការសហការជាមួយតំណាង ពិសេសរបស់លោកអគ្គលេខាធិការ ដោយមានការជួយឧបត្ថម្ភតាមការដែលចាំបាច់ពីអង្គការមនុស្សធម៌ អន្តរជាតិសមស្របផ្សេងៗទៀត និង ពីហត្ថលេខីទាំងឡាយ ។

### មាត្រាទី ២២

ពាក្យថា " ជនស៊ីវិលជាប់ឃុំឃាំង " សំដៅទៅលើគ្រប់បុគ្គលដែលមិនមែនជាឈ្លើយសឹក ហើយដែលបានរួមចំណែកដោយប្រការណាមួយក៏ដោយ ដល់ការតស៊ូដោយអាវុធ ឬ ការតស៊ូនយោបាយ ហើយត្រូវបានចាប់ខ្លួន ឬ ឃាត់ខ្លួនដោយភាគីណាមួយដោយសារការរួមចំណែករបស់ខ្លួននោះ ។

## ភាគទី ៧

## គោលការណ៍សំរាប់រដ្ឋធម្មនុញ្ញថ្មីរបស់កម្ពុជា

### មាត្រាទី ២៣

បណ្ដាគោលការណ៍ជាមូលដ្ឋាន ដោយរួមទាំងគោលការណ៍ស្ដីពីសិទ្ធិមនុស្ស និង សេរីភាពជាមូលដ្ឋាន ក៏ដូចជាគោលការណ៍ស្ដីពីលក្ខន្តិកៈ របស់កម្ពុជាជាប្រទេសអព្យាក្រឹតមួយ ហើយដែលត្រូវតែមានក្នុងរដ្ឋធម្មនុញ្ញកម្ពុជាថ្មី នោះ គឺមានចែងនៅក្នុងឧបសម្ព័ន្ធទី ៥ ។

## ភាគទី ៨

## ការស្ដារនិង កសាងឡើងវិញ

### មាត្រាទី ២៤

បណ្ដាហត្ថលេខីទទួលស្គាល់ថា សហគមន៍អន្តរជាតិផ្ដល់ការគាំទ្រផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុសំរាប់ការស្ដារ និង កសាងប្រទេសកម្ពុជាឡើងវិញ ដូចដែលមានចែងនៅក្នុងសេចក្ដីប្រកាសដោយឡែកមួយ ។

# ភាគទី ៩

## បទបញ្ញត្តិចុងក្រោយ

### មាត្រាទី ២៥

ដោយទឹកចិត្តស្មោះត្រង់ និង ក្នុងស្មារតីសហប្រតិបត្តិការ បណ្ដាហត្ថលេខីទាំងឡាយត្រូវដោះស្រាយដោយសន្តិវិធីនូវរាល់ទំនាស់ ដែលទាក់ទងដល់ការអនុវត្តន៍កិច្ចព្រមព្រៀងនេះ ។

### មាត្រាទី ២៦

ហត្ថលេខីទាំងឡាយស្នើសុំរដ្ឋដទៃផ្សេងទៀត អង្គការអន្តរជាតិនិងអង្គការដទៃទៀត អោយចូលរួមសហការ និង ជួយឧបត្ថម្ភក្នុងការអនុវត្តន៍កិច្ចព្រមព្រៀងនេះ និងក្នុងការបំពេញភារកិច្ចរបស់ អ៊ុនតាក់ "UNTAC" ។

### មាត្រាទី ២៧

ហត្ថលេខីទាំងឡាយត្រូវធ្វើសហប្រតិបត្តិការពេញលេញជាមួយអង្គការសហប្រជាជាតិ ដើម្បីធានាដល់ការអនុវត្តន៍ភារកិច្ចរបស់គេ ដោយរួមទាំងការផ្ដល់បុព្វសិទ្ធិ និង អភ័យឯកសិទ្ធិទាំងឡាយ និង ដោយធានា និង ជួយសម្រួលដល់សេរីភាពក្នុងការធ្វើដំណើរ និង ការទាក់ទងគ្នា ក្នុងទឹកដី និង ក្នុងការកាត់ទឹកដីរបស់ខ្លួន ។

ក្នុងការបំពេញភារកិច្ចរបស់ខ្លួន អ៊ុនតាក់ "UNTAC" ត្រូវអនុវត្តដោយគោរពដោយសមស្របនូវអធិបតេយ្យភាពនៃរដ្ឋទាំងអស់ដែលនៅជិតខាងកម្ពុជា ។

### មាត្រាទី ២៨

១- បណ្ដាហត្ថលេខីទាំងត្រូវធ្វើតាមដោយស្មោះស្ម័គ្រនូវរាល់កាតព្វកិច្ចដែលមានសន្យានៅក្នុងកិច្ចព្រមព្រៀងនេះ ហើយត្រូវធ្វើសហប្រតិបត្តិការពេញលេញជាមួយអង្គការសហប្រជាជាតិ រួមទាំងការផ្ដល់ពត៌មានដែល អ៊ុនតាក់ "UNTAC" ត្រូវការក្នុងការបំពេញភារកិច្ចរបស់ខ្លួន ។

២- ការចុះហត្ថលេខា តំណាងអោយប្រទេសកម្ពុជា ដោយបណ្ដាសមាជិកអេសអ៊ិនស៊ី ត្រូវបានចាត់ទុកថាជាការសន្យាគោរព ដោយភាគី និង កងទ័ពកម្ពុជាទាំងអស់ ចំពោះប្រការទាំងឡាយនៃកិច្ចព្រមព្រៀងនេះ ។

### មាត្រាទី ២៩

ដោយមិនធ្វើអោយប៉ះពាល់ដល់បុព្វសិទ្ធិរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ហើយយោងតាមសំណើរបស់លោកអគ្គលេខាធិការ សហប្រធានទាំងពីរនៃសន្និសីទប៉ារីសស្ដីពីកម្ពុជា ក្នុងករណីដែលមាន ការរំលោភ ឬគំរាមកំហែងនឹងមានការរំលោភដល់កិច្ចព្រមព្រៀងនេះ នឹងត្រូវធ្វើការពិគ្រោះយោបល់ស្របជាបន្ទាន់រួមទាំងជាមួយបណ្ដាសមាជិកសន្និសីទក្រុងប៉ារីសស្ដីពីកម្ពុជាដើម្បីចាត់វិធានការសមស្របធានាដល់ការគោរពការសន្យាទាំងនេះ ។

## មាត្រា ៣០

កិច្ចព្រមព្រៀងនេះនឹងចូលជាធរមានចាប់តាំងពីពេលចុះហត្ថលេខានេះតទៅ ។

## មាត្រា ៣១

កិច្ចព្រមព្រៀងនេះនឹងត្រូវទុកចំហសំរាប់ការចូលជាភាគីរបស់រដ្ឋទាំងអស់ ។ ឯកសារផ្លូវការនៃការចូលរួម ត្រូវតម្កល់ទុកជាមួយរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង និង រដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌូនេស៊ី ។ ចំពោះរដ្ឋនីមួយៗ ដែលយល់ព្រមចូលរួមនៅក្នុងកិច្ចព្រមព្រៀងនេះ កិច្ចព្រមព្រៀងត្រូវចូលជាធរមានចាប់តាំងពីពេលតម្កល់ឯកសារផ្លូវការសុំចូលរបស់ខ្លួន ។ បណ្តារដ្ឋដែលបានសុំចូលត្រូវជាប់បញ្ញត្តិ និងកាតព្វកិច្ចដូចគ្នានឹងរដ្ឋហត្ថលេខីដទៃទៀតដែរ ។

## មាត្រា ៣២

ច្បាប់ដើមនៃកិច្ចព្រមព្រៀងនេះ ដែលអត្ថបទធ្វើជាភាសាចិន - អង់គ្លេស - បារាំង - ខ្មែរ និង រុស្ស៊ី មានតម្លៃដូចគ្នា នឹងត្រូវ តម្កល់រក្សាទុកជាមួយរដ្ឋាភិបាលសាធារណរដ្ឋបារាំង និង រដ្ឋាភិបាលសាធារណរដ្ឋឥណ្ឌូនេស៊ី ដែលនឹងផ្ញើនូវច្បាប់ចម្លងត្រឹមត្រូវតាមច្បាប់ដើមទៅជូនរដ្ឋាភិបាលនៃរដ្ឋឯទៀតដែលបានចូលរួមនៅក្នុងសន្និសីទក្រុងប៉ារីសស្តីពីកម្ពុជា និងជូនទៅលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

ដើម្បីជាសក្ខីភាព បណ្តាប្រតិភូពេញសមត្ថកិច្ចដូចមានរាយនាមខាងក្រោម ដែលបានទទួលសិទ្ធិត្រឹមត្រូវហើយនោះ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ។

*ធ្វើនៅក្រុងប៉ារីស ថ្ងៃទី ២៣ ខែ តុលា ឆ្នាំមួយពាន់ប្រាំបួនរយកៅសិបមួយ*

ឧបសម្ព័ន្ធទី ១

ភារកិច្ចរបស់ អាជ្ញាធរបណ្តោះអាសន្ន អ.ស.ប នៅកម្ពុជា "អ៊ុនតាក់"

# ជំពូក ក : និតិក្រមរួម

១. ស្របតាមមាត្រាទី ៦ នៃកិច្ចព្រមព្រៀង អ៊ុនតាក់នឹងអនុវត្តអំណាចដែលចាំបាច់ ដើម្បីធានាការអនុវត្តន៍កិច្ចព្រមព្រៀងនេះ ដោយគិតទាំងអំណាចដែលទាក់ទងទៅនឹងការរៀបចំនិងការដឹកនាំការបោះឆ្នោតដោយសេរីនិងត្រឹមត្រូវ ព្រមទាំងទិដ្ឋភាពទាំងឡាយនៃ រដ្ឋបាលនៃប្រទេសកម្ពុជាដែលទាក់ទងទៅនឹងបញ្ហានេះ ។

២. យន្តការខាងក្រោមនេះ នឹងត្រូវប្រើប្រាស់ដើម្បីដោះស្រាយបញ្ហាទាំងអស់ទាក់ទងទៅនឹង ការអនុវត្តន៍ កិច្ចព្រមព្រៀងនេះដែលអាចកើតមានឡើងរវាងតំណាងពិសេសរបស់លោកអគ្គលេខាធិការ និងក្រុមប្រឹក្សាជាតិជាន់ខ្ពស់ "អេសអិន-ស៊ី" :

ក. អេសអិនស៊ីត្រូវជូនបតិណែនាំដល់ អ៊ុនតាក់ ដែលត្រូវគោរពតាមបតិណែនាំនេះ ដរាបណាមាន កុងសង់ស៊ុស ក្នុងចំណោមសមាជិកអេសអិនស៊ី ហើយដរាបណាបតិណែនាំនោះវាស្របនឹងទិសដៅ នៃកិច្ចព្រមព្រៀងនេះ

ខ. បើសិនជាគ្មានកុងសង់ស៊ុសក្នុងចំណោមសមាជិកអេសអិនស៊ីនោះទេ ទោះបីជាមានការខិតខំប្រឹងប្រែងរបស់ប្រធានក៏ដោយ សម្តេចនរោត្តមសីហនុជាប្រធានអេសអិនស៊ី នោះនឹងមានសិទ្ធិធ្វើសេចក្តីសំរេចពីការជូនបតិណែនាំ ដល់អ៊ុនតាក់ដោយយកចិត្តទុកដាក់គិតគូរទាំងស្រុងទៅដល់ ទស្សនៈទាំងឡាយដែលបានសំដែងឡើងនៅក្នុង អេសអិនស៊ី ។ អ៊ុនតាក់នឹងគោរពតាមបតិណែនាំនោះ ក្នុងករណីបតិណែនាំនោះសមស្របទៅនឹងទិសដៅនៃកិច្ចព្រមព្រៀងនេះ

គ. បើសិនជាសម្តេចនរោត្តម សីហនុ ប្រធានអេសអិនស៊ី តំណាងស្របច្បាប់នៃអធិបតេយ្យភាពកម្ពុជា មិនអាចសំរេចបាន ក្នុងករណីណាមួយនោះ សិទ្ធិនៃសេចក្តីសំរេចរបស់សម្តេច នឹងផ្ទេរទៅអោយតំណាងពិសេសរបស់លោកអគ្គលេខាធិការអ.ស.ប ។ តំណាងពិសេសនឹងធ្វើសេចក្តីសំរេចចុងក្រោយដោយយកចិត្តទុកដាក់គិតគូរទាំងស្រុងទៅដល់ទស្សនៈទាំងឡាយដែលបានសំដែងឡើងនៅក្នុងអេសអិនស៊ី ។

ឃ. សិទ្ធិអំណាចណាដែលទាក់ទិនទៅនឹងការអនុវត្តន៍កិច្ចព្រមព្រៀងនេះដែលបានប្រគល់អោយអេសអិនស៊ីតាមកិច្ចព្រមព្រៀង នឹងត្រូវអនុវត្តដោយកុងសង់ស៊ុស ឬបើសិនមិនសំរេចបានកុងសង់ស៊ុសនោះទេ

សិទ្ធិ អំណាចនោះនិងត្រូវ អនុវត្តដោយប្រធានអេសអិនស៊ី ដោយយោងតាមវិធិក្រមដែលបានរៀបរាប់ខាងលើ ។ ក្នុងករណីដែលសម្តេចនរោត្តម សីហនុ ប្រធានអេសអិនស៊ី តំណាងស្របច្បាប់នៃអធិបតេយ្យភាពកម្ពុជា មិនអាចសំរេចបានក្នុងករណីណាមួយនោះ សិទ្ធិសំរេចរបស់សម្តេចនេះនឹងត្រូវផ្ទេរទៅអោយតំណាងពិសេសរបស់លោកអគ្គលេខាធិការ អ.ស.ប ដែលអាចប្រកាន់យកនូវវិធានការចាំបាច់នានា ។

៤_ ក្នុងករណីទាំងអស់ តំណាងពិសេសរបស់អគ្គលេខាធិការអ.ស.ប និងកំណត់ថាតើបទដៃណែនាំឬវិធានការរបស់អេសអិនស៊ី ស្របទៅនឹងកិច្ចព្រមព្រៀងឬទេ ។

៣_ តំណាងពិសេសនៃលោកអគ្គលេខាធិការ ឬប្រតិភូរបស់គាត់ត្រូវចូលរួមអង្គប្រជុំទាំងឡាយរបស់អេសអិនស៊ី និងរបស់ស្ថាប័នបន្ទាប់ណាទៀតដែលអាចបង្កើតដោយ អេសអិនស៊ី ហើយត្រូវជូនដល់សមាជិក អេសអិនស៊ី អំពីរាល់ព័ត៌មានចាំបាច់ទាំងអស់អំពីបណ្តាសេចក្តីសំរេចរបស់អ៊ុនតាក់ ។

# ជំពូក ខ : រដ្ឋបាលស៊ីវិល

១_ ស្របតាមមាត្រាទី ៦ នៃកិច្ចព្រមព្រៀងនេះ អង្គការ ស្ថាប័ននិងការិយាល័យរដ្ឋបាលទាំងអស់ដែលមានតួនាទីក្នុងវិស័យការបរទេស ការពារជាតិ ហិរញ្ញវត្ថុ សន្តិសុខសាធារណៈ និងឃោសនាការ នឹងត្រូវដាក់អោយស្ថិតនៅក្រោមការត្រួតពិនិត្យដោយផ្ទាល់របស់អ៊ុនតាក់ ដែលត្រូវត្រួតពិនិត្យតាមការចាំបាច់ដើម្បីធានារក្សាក្រឹតភាពមួយដ៏ហ្មត់ចត់ ។

ក្នុងន័យនេះ តំណាងពិសេសរបស់លោកអគ្គលេខាធិការ ត្រូវកំណត់បញ្ជីដែលចាំបាច់ ហើយគាត់អាចចេញបទបញ្ជាទៅដល់បណ្តាអង្គការស្ថាប័ននិងការិយាល័យរដ្ឋបាលខាងលើនេះ ។ បទបញ្ជាទាំងនេះ អាចបញ្ជូនចេញទៅចំពោះភាគីកម្ពុជាទាំងអស់ ហើយអាចជាបទបញ្ជាចំពោះភាគីកម្ពុជាទាំងអស់ផង ។

២_ ស្របតាមមាត្រាទី ៦ នៃកិច្ចព្រមព្រៀង តំណាងពិសេសរបស់លោកអគ្គលេខាធិការ ដោយមានការពិគ្រោះជាមួយអេសអិនស៊ី ត្រូវកំណត់ថា តើអង្គការ ស្ថាប័ន និងការិយាល័យរដ្ឋបាលណាទៀតដែលអាចជះឥទ្ធិពលផ្ទាល់ ដល់លទ្ធផលនៃការបោះឆ្នោត ។ អង្គការ ស្ថាប័ន និងការិយាល័យរដ្ឋបាលអស់ទាំងនេះត្រូវដាក់នៅក្រោមការពិនិត្យ ឬត្រួតពិនិត្យដោយផ្ទាល់របស់អ៊ុនតាក់ ហើយត្រូវគោរពតាមការណែនាំទាំងឡាយរបស់អ៊ុនតាក់ ។

៣_ ស្របតាមមាត្រាទី ៦ នៃកិច្ចព្រមព្រៀង តំណាងពិសេសនៃលោកអគ្គលេខាធិការ ដោយមានការពិគ្រោះជាមួយអេសអិនស៊ី និងពិនិត្យមើលថា តើអង្គការ ស្ថាប័ន និងការិយាល័យរដ្ឋបាលណា អាចបន្ត ប្រតិបត្តិការតទៅទៀត ដើម្បីធានាដល់ជីវភាពធម្មតាប្រចាំថ្ងៃនៅប្រទេសកម្ពុជា ហើយ បើសិនជាចាំបាច់ ដោយស្ថិតក្រោមការពិនិត្យរបស់អ៊ុនតាក់ តាមការដែលអ៊ុនតាក់យល់ថាចាំបាច់ ។

៤- ស្របតាមមាត្រាទី ៦ នៃកិច្ចព្រមព្រៀង សិទ្ធិអំណាចរបស់តំណាងពិសេសនៃលោកអគ្គលេខាធិការត្រូវមានអំណាចដើម្បី :

ក- តែងតាំងបុគ្គលិករបស់អង្គការសហប្រជាជាតិ ទៅក្នុងអង្គការ ស្ថាប័ននិងការិយាល័យរដ្ឋបាល របស់ភាគីកម្ពុជាទាំងអស់ ដែលនឹងមានសិទ្ធិចូលទាក់ទងដោយគ្មានការហាមឃាត់ជាមួយរាល់កិច្ច ប្រតិបត្តិការផ្នែករដ្ឋបាល និង ពត៌មាន ។

ខ- ទាមទារអោយផ្លាស់ប្តូរទៅកន្លែងថ្មី ឬអោយដកហូតនូវបុគ្គលិកណាមួយរបស់បណ្តាអង្គការស្ថាប័ន និងការិយាល័យរដ្ឋបាលនេះ

៥- ក- ផ្អែកទៅលើពត៌មានដែលចែងនៅក្នុងមាត្រាទី ១ កថាខ័ណ្ឌ ៣ នៃឧបសម្ព័ន្ធ ២ តំណាងពិសេសរបស់លោកអគ្គលេខាធិការ ក្រោយពីមានការពិគ្រោះជាមួយភាគីកម្ពុជា នឹងកំណត់នូវប៉ូលីសស៊ីវិលជាចាំបាច់ដើម្បីអនុវត្តច្បាប់នៅកម្ពុជា ។ ក្នុងករណីនេះ ភាគីកម្ពុជាទាំងអស់សន្យានឹងគោរពនូវការកំណត់ដែលធ្វើឡើងដោយតំណាងពិសេសរបស់លោក អគ្គលេខាធិការ ។

ខ- ប៉ូលីសស៊ីវិលទាំងអស់ នឹងប្រតិបត្តិការក្រោមការពិនិត្យមើលឬការត្រួតពិនិត្យរបស់អ៊ុនតាក់ ដើម្បីធានាការរក្សាច្បាប់និងសណ្តាប់ធ្នាប់ដោយប្រសិទ្ធភាពនិងមិនលំអៀង ហើយសិទ្ធិមនុស្ស និងសេរីភាព ជាមូលដ្ឋានត្រូវបានគោរពទាំងស្រុង ។ ដោយមានការពិគ្រោះជាមួយអេសអិនស៊ី អ៊ុនតាក់ត្រូវពិនិត្យមើលនូវដំណើរការអនុវត្តន៍ច្បាប់ និងតុលាការផងដែរនៅទូទាំងប្រទេសកម្ពុជាដែលចាំបាច់ ដើម្បីធានាការសំរេចនូវទិសដៅទាំងនោះ ។

៦- បើតំណាងពិសេសរបស់លោកអគ្គលេខាធិការយល់ថាចាំបាច់ ដោយមានការពិគ្រោះជាមួយអេសអិនស៊ី អ៊ុនតាក់នឹង ស៊ើបអង្កេតករណីផ្សេងៗ និងការចោទប្រកាន់ស្តីពីសកម្មភាពដែលរចនាសម្ព័ន្ធរដ្ឋបាល ដែលមិនសមស្រប ឬ ដែលប្រឆាំងនឹងបណ្តាទិសដៅនៃដំណោះស្រាយនយោបាយរួមនេះ ។ អ៊ុនតាក់ ក៏ត្រូវមានអំណាចស៊ើបអង្កេតបែបនេះតាមគំនិតខ្លួនផ្ទាល់ ដែរ ។ នៅពេលចាំបាច់ អ៊ុនតាក់នឹងចាត់វិធានការកែតំរូវដ៏សមស្រប ។

# ជំពូក គ : មុខងារខាងយោធា

១- អ៊ុនតាក់នឹងពិនិត្យមើល តាមដាន និងបញ្ជាក់មើលការដក / បរទេស ការឈប់បាញ់ និងបណ្តាវិធានការទាក់ទងទាំងឡាយស្របតាមឧបសម្ព័ន្ធទី ២ រួមមាន :

ក- បញ្ជាក់ការដកកងកម្លាំង ទីប្រឹក្សានិងបុគ្គលិកយោធាបរទេសគ្រប់ប្រភេទទាំងអស់ ព្រមទាំងអាវុធ

គ្រាប់រំសេវ និងសម្ភាររបស់គេ ចេញពីកម្ពុជា និងការមិនវិលត្រឡប់របស់គេចូលមក កម្ពុជាវិញ

ខ. ទាក់ទងជាមួយរដ្ឋាភិបាលប្រទេសជិតខាង ស្តីពីព្រឹត្តិការណ៍ណាដែលកើតឡើងនៅក្នុងឬនៅជិតទឹកដីខ្លួនដែលអាចបណ្តាលឲ្យគ្រោះថ្នាក់ដល់ការអនុវត្តកិច្ចព្រមព្រៀងនេះ.

គ. តាមដានការបញ្ឈប់ជំនួយយោធាបរទេសដល់ភាគីកម្ពុជាទាំងអស់

ឃ. ស្វែងរកនិងរឹបអូសយកកន្លែងដាក់គ្រឿងសព្វាវុធ និងសម្ភារខាងយោធាដែលគេកប់លាក់ទុកទូទាំងប្រទេស

ង. ជួយបោសសំអាតមីន និងដំណើរការកម្មវិធីហាត់រៀន អំពីការបោសសំអាតមីន និងកម្មវិធីយល់ដឹងពីមីនក្នុងចំណោមប្រជាជនកម្ពុជា ។

២. អ៊ុនតាក់នឹងពិនិត្យមើលការប្រមូលផ្តុំនិងការដាក់ទីតាំងឡើងវិញនៃកងកម្លាំងទាំងអស់នៅកន្លែង ជំរំបន្ទាយដែលបានកំណត់ច្បាស់លាស់ ដោយផ្អែកទៅលើប្រតិទិនប្រតិបត្តិការមួយ ដែលត្រូវបានព្រមព្រៀងគ្នា ស្របតាមឧបសម្ព័ន្ធ ២ ។

៣. បន្ទាប់ពីកងកម្លាំងចូលនៅក្នុងជំរំបន្ទាយ អ៊ុនតាក់នឹងផ្តើមដំណើរការត្រួតពិនិត្យនិងកាត់បន្ថយសព្វាវុធដូចដែលបានបញ្ជាក់ក្នុងឧបសម្ព័ន្ធ ២ ។

៤. អ៊ុនតាក់ ត្រូវតាមដានការចាំបាច់ស្តីពីដំណើរការរំសាយជាបណ្តើរៗ នូវកងកំលាំងយោធានៃបណ្តាភាគី ស្របតាមឧបសម្ព័ន្ធ ២ ។

៥. អ៊ុនតាក់ ត្រូវជួយតាមដែលចាំបាច់ដល់គណៈកម្មការកាកបាទក្រហមអន្តរជាតិក្នុងការដោះលែង ឈ្លើយសឹក និងជនស៊ីវិលជាប់ឃុំឃាំងទាំងអស់ ។

## ជំពូក ឃ : ការបោះឆ្នោត

១. អ៊ុនតាក់ត្រូវរៀបចំនិងដឹកនាំការបោះឆ្នោតដែលមានចែងក្នុងភាគ ២ នៃកិច្ចព្រមព្រៀងនេះ ស្របតាមជំពូកនេះនិងឧបសម្ព័ន្ធទី ៣ ។

២. អ៊ុនតាក់អាចពិគ្រោះជាមួយអេសអិនស៊ី អំពីការរៀបចំនិងការដឹកនាំដំណើរការបោះឆ្នោត ។

៣. ក្នុងការអនុវត្តនូវការទទួលខុសត្រូវរបស់ខ្លួនក្នុងដំណើរការបោះឆ្នោត សិទ្ធិអំណាចច្បាស់លាស់របស់អ៊ុនតាក់រួមមានដូចតទៅនេះ :

ក. ដោយមានការពិគ្រោះជាមួយអេសអិនស៊ី បង្កើតប្រព័ន្ធច្បាប់ ទំរង់បែបបទ និងវិធានការរដ្ឋបាលទាំងឡាយដែលចាំបាច់សំរាប់រៀបចំការបោះឆ្នោតដោយសេរីនិងត្រឹមត្រូវនៅកម្ពុជា រាប់ទាំងការអនុម័ត

នូវច្បាប់បោះឆ្នោតនិងបទបញ្ជាសីលធម៌ផ្សេងៗ ដែលបានចែងអំពីការចូលរួមក្នុងការបោះឆ្នោតធ្វើយ៉ាងណា អោយសមស្របទៅនឹងការគោរពសិទ្ធិមនុស្សនិងការហាមឃាត់ការបង្ខិតបង្ខំឬការអូសទាញតាមមធ្យោបាយហិរញ្ញវត្ថុ ដើម្បីជះឥទ្ធិពលទៅលើចំណូលចិត្តរបស់អ្នកបោះឆ្នោត

ខ- ផ្អាកឬលុបបំបាត់ចោល ដោយមានការពិគ្រោះជាមួយអេសអិនស៊ី នូវបទបញ្ញត្តិច្បាប់ដែលមានស្រាប់ណាដែលអាចធ្វើអោយបរាជ័យដល់កម្មវត្ថុ និងគោលបំណងនៃកិច្ចព្រមព្រៀងនេះ

គ- តាក់តែងនិងអនុវត្តកម្មវិធីមួយអប់រំដល់អ្នកបោះឆ្នោតរួមមានទិដ្ឋភាពទាំងអស់នៃការបោះឆ្នោត ដើម្បីគាំទ្រដល់ដំណើរការបោះឆ្នោត

ឃ- តាក់តែងនិងអនុវត្តប្រព័ន្ធចុះឈ្មោះអ្នកបោះឆ្នោតមួយ ដែលជាដំណាក់កាលទី ១ នៃដំណើរការបោះឆ្នោត ដើម្បីធានាអោយអ្នកដែលមានសិទ្ធិបោះឆ្នោតមានឱកាសទៅចុះឈ្មោះ និងរៀបចំតទៅទៀតនូវបញ្ជីចុះឈ្មោះអ្នកបោះឆ្នោតដែលបានបញ្ជាក់ហើយ

ង- តាក់តែងនិងអនុវត្តប្រព័ន្ធចុះឈ្មោះ មួយនៃគណៈបក្សនយោបាយនិងបញ្ជីបេក្ខជន

ច- ធានាការចូលទាក់ទងដ៏សមរម្យជាមួយប្រព័ន្ធឃោសនា រួមទាំងកាសែត ទូរទស្សន៍ និងវិទ្យុ សំរាប់គណៈបក្សនយោបាយទាំងអស់ដែលប្រកួតប្រជែងក្នុងការបោះឆ្នោត

ឆ- អនុម័តនិងអនុវត្តវិធានការទាំងឡាយ ដើម្បីតាមដាននិងសំរួលការចូលរួមរបស់ប្រជាជនកម្ពុជានៅក្នុងការបោះឆ្នោត យុទ្ធនាការឃោសនានយោបាយ និងទំរង់បែបបទនៃការបោះសន្លឹកឆ្នោត

ជ- តាក់តែងនិងអនុវត្តប្រព័ន្ធរៀបចំបោះឆ្នោតនិងវិធីបោះសន្លឹកឆ្នោត ដើម្បីធានាអោយអ្នកដែលមានឈ្មោះបោះឆ្នោតមានលទ្ធភាពបោះឆ្នោត

ឈ- ដោយពិគ្រោះជាមួយអេសអិនស៊ី បង្កើតអោយមានការរៀបចំសំរបសំរួលគ្នាដើម្បីសំរួលដល់វត្តមាននៃអ្នកសង្កេតការណ៍បរទេសដែលចង់មកសង្កេតយុទ្ធនាការឃោសនានិងការបោះឆ្នោត

ញ- ដឹកនាំជាទូទៅនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត

ដ- ពិនិត្យមើលនិងស៊ើបអង្កេតអំពីការប្តឹងតវ៉ា ស្តីពីអំពើមិនត្រឹមត្រូវក្នុងការបោះឆ្នោត ព្រមទាំងនឹងចាត់វិធានការកែតំរូវដ៏សមស្រប

ឋ- កំណត់ថា តើការបោះឆ្នោត ប្រព្រឹត្តទៅដោយសេរីនិងត្រឹមត្រូវឬ ទេ ហើយបើសេរីនិងត្រឹមត្រូវហើយ ចេញសេចក្តីបញ្ជាក់បញ្ជីឈ្មោះអ្នកដែលបានជាប់ឆ្នោតត្រឹមត្រូវ ។

៤- ក្នុងការអនុវត្តនូវការទទួលខុសត្រូវរបស់ខ្លួន [illegible] អ៊ុនតាក់ត្រូវបង្កើតប្រព័ន្ធ ការពារមួយដើម្បីជួយខ្លួន អោយធានាបានថាគ្មានការលួចបន្លំក្នុងដំណើរការបោះឆ្នោត រួមទាំងការរៀបចំអោយបណ្តាញតាមដានកម្ពុជាចូល សង្កេតបែបបទចុះឈ្មោះនិងបោះឆ្នោត ព្រមទាំងបង្កើតយន្តការ របស់អ៊ុនតាក់មួយសំរាប់ទទួលពាក្យបណ្តឹងនិងសំរេចរឿងពីការប្តឹងតវ៉ា ។

៥- ប្រតិទិនសំរាប់ដំណាក់កាលផ្សេងៗនៃដំណើរការបោះឆ្នោតត្រូវកំណត់ដោយអ៊ុនតាក់ ដោយមានការពិគ្រោះជាមួយអេសអិនស៊ី ដូចដែលមានចែងក្នុងកថាខ័ណ្ឌទី ២ នៃជំពូកនេះ ។ ដំណើរការបោះឆ្នោតមានរយៈពេលមិនលើសពី ៨ ខែចាប់ពីពេលផ្តើមចុះបញ្ជីឈ្មោះអ្នកបោះឆ្នោត ។

៦- ក្នុងការរៀបចំនិងដឹកនាំដំណើរការបោះឆ្នោត អ៊ុនតាក់ត្រូវខិតខំគ្រប់បែបយ៉ាងដើម្បីធានាថាប្រព័ន្ធនិងបែបបទដែលបានអនុម័តនោះពិតជាគ្មានលំអៀងដាច់ខាត ទន្ទឹមគ្នានឹងការរៀបចំប្រតិបត្តិការទាំងឡាយ ខាងផ្នែករដ្ឋបាលត្រូវអោយងាយស្រួល និងប្រសិទ្ធភាពបំផុតដែលអាចធ្វើទៅបាន ។

## ជំពូក ខ : សិទ្ធិមនុស្ស

ស្របតាមមាត្រា ទី ១៦ អ៊ុនតាក់ត្រូវរៀបចំបែបបទទាំងឡាយសំរាប់ :

ក- ការតាក់តែងនិងការអនុវត្តនូវកម្មវិធីអប់រំអំពីសិទ្ធិមនុស្សមួយ ដើម្បីជំរុញការគោរព និង ការយល់ដឹងអំពីសិទ្ធិមនុស្ស ។

ខ- ការឃ្លាំមើលជាទូទៅ អំពីសិទ្ធិមនុស្សក្នុងដំណាក់កាលអន្តរកាល ។

គ- ការស៊ើបអង្កេតការប្តឹងតវ៉ាអំពីសិទ្ធិមនុស្ស និងការប្រកាន់យកវិធានការកែតំរូវ នៅទីណាដែលសមស្រប ។

# ឧបសម្ព័ន្ធទី ២

## ការដកកងកំលាំងការឈប់បាញ់ និង វិធានការពាក់ព័ន្ធ

## មាត្រា ១

## ការឈប់បាញ់

១- គ្រប់ភាគីកម្ពុជាទាំងអស់ ចាប់ពីនេះទៅហៅ " បណ្ដាភាគី " យល់ព្រមអនុវត្តការឈប់បាញ់ ទាំងស្រុងមួយ លើដីគោក លើ ទឹក និងលើអាកាស ។ ការឈប់បាញ់នេះនឹងត្រូវអនុវត្តជាពីរដំណាក់កាល ។ នៅក្នុងដំណាក់កាលទី ១ ការឈប់បាញ់ នឹងត្រូវអនុវត្តដោយមានការជួយគាំទ្រពីលោកអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ តាមរយៈការជួយឧបត្ថម្ភរបស់ លោក ។ នៅក្នុងដំណាក់កាលទី ២ ដែលគប្បីចាប់ផ្ដើមអោយបានឆាប់រហ័សតាមដែលអាចធ្វើទៅបានការឈប់បាញ់ត្រូវ បានពិនិត្យមើលតាមដាន និងបញ្ជាក់ដោយអ៊ុនតាក់ ។ មេបញ្ជាការផ្នែកយោធារបស់ អ៊ុនតាក់ ដោយមានពិគ្រោះពិភាក្សា ជាមួយបណ្ដាភាគីនឹងកំណត់ពីពេលវេលា និងកាលបរិច្ឆេទពិតប្រាកដនៃការចាប់ផ្ដើមដំណាក់កាលទី ២ ។ កាលបរិច្ឆេទនេះ ត្រូវកំណត់ យ៉ាងតិច ៤ សប្ដាហ៍មុនពេលចូលជាធរមាននៃដំណាក់កាលទី ២ នេះ ។

២- បណ្ដាភាគីសន្យាថា ចាប់ពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះទៅ គេត្រូវគោរពតាម ការឈប់បាញ់ ហើយត្រូវបញ្ជាកង[illegible]របស់ខ្លួនជាបន្ទាន់អោយដោះដៃចេញពីការប្រយុទ្ធ និង ជៀសវាងមិនធ្វើសកម្មភាពប្រទូសរ៉ាយហើយ មិនពង្រាយកងទ័ព ចលនាទ័ពឬក៏ធ្វើសកម្មភាពណាមួយដែលនាំអោយពង្រីកទឹកដីដែលខ្លួនកាន់កាប់ ឬដែលនាំអោយកើត ការប្រយុទ្ធគ្នាជាថ្មីទៀតវិញ ក្នុងពេលរង់ចាំដំណាក់កាលទី ២ ចាប់ផ្ដើមនេះ ។

គេបានឯកភាពគ្នាថា ពាក្យ "កងកំលាំង" គឺរាប់បញ្ចូលកងទ័ពស្រួច ទ័ពខេត្ត ទ័ពស្រុក ស្វ័យត្រាណ ហើយនិងទ័ព ជំនួយផ្សេងៗទាំងអស់ ។ នៅក្នុងរយៈពេលនៃដំណាក់កាលទី ១ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ នឹងផ្ដល់នូវការ ជួយឧបត្ថម្ភរបស់លោកដល់បណ្ដាភាគី ដើម្បីជួយគេក្នុងការអនុវត្តន៍ដំណាក់កាលទី ១ នេះ ។ បណ្ដាភាគីសន្យាសុខចិត្តធ្វើ សហប្រតិបត្តិការជាមួយលោកអគ្គលេខាធិការ ឬជាមួយតំណាងរបស់លោកក្នុងការប្រើប្រាស់ការជួយឧបត្ថម្ភរបស់ លោកក្នុងបញ្ហានេះ ។

៣- ភាគីទាំងនោះយល់ព្រមថា បន្ទាប់ពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះភ្លាម ពត៌មានដូចខាងក្រោម នឹងត្រូវ ផ្ដល់អោយដល់អង្គការសហប្រជាជាតិ :

ក- កំលាំងកងទ័ពទាំងអស់របស់ខ្លួន អង្គការចាត់តាំង ចំនួននិងកន្លែងពង្រាយទ័ពច្បាស់លាស់ នៅក្នុង និងក្រៅ ប្រទេសកម្ពុជា ។ កន្លែងទីតាំងពង្រាយទ័ពត្រូវគូសដៅលើផែនទីមួយ ដែលដៅទីតាំងទ័ព ឈរជើងទាំងអស់ ទោះជានៅទីនោះ មានទ័ពនៅកាន់កាប់ឬក៏គ្មានក្ដី ដោយរាប់ទាំងបណ្ដាជំរំរៀបចំទ័ព បណ្ដាមូលដ្ឋានផ្គត់ផ្គង់និងផ្លូវផ្គត់ផ្គង់ ។

ខ-បញ្ជីបរិមាណអាវុធ គ្រាប់រំសេវនិងសម្ភារៈដែលកងកំលាំងរបស់ខ្លួនកាន់កាប់ ហើយនិងទីតាំង ពិតប្រាកដនានា ដែលអាវុធគ្រាប់រំសេវនិងសម្ភារៈទាំងនោះកំពុងដាក់ពង្រាយ ។

គ-បញ្ជីកត់ត្រាលំអិតនៃចំការមីនរបស់ពួកគេ រាប់បញ្ចូលទាំងបែបបទនិងលក្ខណៈសម្បត្តិទាំងឡាយនៃមីនៈ ដែលគេដាក់ និងពត៌មានពីមីនអន្ទាក់ ប្រើដោយពួកគេ ព្រមទាំងរាល់ពត៌មានដែលគេអាចទទួលបានពីចំការមីន ឬមីនអន្ទាក់ដែល ដាក់ប្រើដោយភាគីឯទៀត ។

ឃ-កំលាំងសរុបនៃកំលាំងប៉ូលីសរបស់ខ្លួន អង្គការចាត់តាំង ចំនួននិងកន្លែងពង្រាយកំលាំងឲ្យពេញលេញ ព្រមទាំងបញ្ជីបរិមាណអាវុធ គ្រាប់រំសេវ និងសម្ភារៈ ហើយនិងទីកន្លែងពិតប្រាកដ ដែលអាវុធគ្រាប់រំសេវ និងសម្ភារៈកំពុងដាក់ពង្រាយ ។

៤- នៅពេលមកដល់កម្ពុជាភ្លាម ហើយមិនឲ្យហួសពីបួនសប្តាហ៍ មុនចាប់ផ្តើមដំណាក់កាលទី ២ មេបញ្ជាការផ្នែកយោធានៃអ៊ុនតាក់ ដោយមានការពិគ្រោះជាមួយភាគីទាំងឡាយ ត្រូវសំរេចបញ្ចប់ ផែនការរបស់ អ៊ុនតាក់ សំរាប់ប្រមូលផ្តុំ និងដាក់ក្នុងបន្ទាយនៃកងកំលាំងរបស់ភាគីទាំងនោះ និង សំរាប់រក្សាទុកអាវុធ គ្រាប់រំសេវ និងសម្ភារៈ ស្របតាមមាត្រា ៣ នៃឧបសម្ព័ន្ធនេះ ។ ផែនការនេះ និងរាប់បញ្ចូលទាំងការជ្រើសរើសតំបន់ប្រមូលផ្តុំនិងតំបន់បន្ទាយ ក៏ដូចជាប្រតិទិនមួយដែល បានព្រមព្រៀងគ្នាហើយ ។ តំបន់បន្ទាយប្រមូលផ្តុំត្រូវរៀបចំឡើងសំរាប់ទំហំកងវរសេនាតូចឬធំជាងនេះ ។

៥- ភាគីទាំងអស់យល់ព្រមចាត់វិធានការ ដើម្បីផ្តល់ពត៌មានដល់កងកំលាំងរបស់ខ្លួនយ៉ាងតិច ២ សប្តាហ៍ មុនចាប់ផ្តើមដំណាក់កាលទី ២ ដោយប្រើគ្រប់មធ្យោបាយទាក់ទងគ្នាដែលមាន អំពីកាលបរិច្ឆេទ និងពេលវេលាដែលបានយល់ព្រម អំពីការចាប់ផ្តើមដំណាក់កាលទី ២ អំពីផែនការដែលបានយល់ព្រមសំរាប់ ការប្រមូលផ្តុំនិងការដាក់ក្នុងបន្ទាយនៃកងកំលាំង របស់ពួកគេ និងសំរាប់ការរក្សាទុកអាវុធ គ្រាប់រំសេវ និងសំភារៈរបស់ពួកគេ និងជាពិសេសអំពីកន្លែងពិតប្រាកដនៃតំបន់ ប្រមូលផ្តុំដែលបណ្តាកងកំលាំងត្រូវទៅចង្កោមខ្លួននោះ ។ ពត៌មានបែបនេះត្រូវបន្តផ្សព្វផ្សាយក្នុងរយៈពេល ៤ សប្តាហ៍ក្រោយ ការចាប់ផ្តើមដំណាក់កាលទី ២ ។

៦- បណ្តាភាគីត្រូវគោរពប្រតិបត្តិតាមយ៉ាងទៀងទាត់បំផុតការឈប់បាញ់ ហើយមិនត្រូវបង្កឡើងវិញនូវការ ប្រទូសរ៉ាយណាតាមផ្លូវគោក ផ្លូវទឹកឬផ្លូវអាកាសទៀយ ។ មេបញ្ជាការនៃកងកំលាំងប្រដាប់អាវុធ ត្រូវធ្វើយ៉ាងណា បណ្តាកងទ័ពទាំងអស់ ក្រោមបញ្ជាការរបស់ខ្លួន ស្ថិតនៅ ក្នុងទីតាំងរៀងខ្លួន ដោយរង់ចាំធ្វើចលនាទៅតំបន់ប្រមូលផ្តុំដែល បានកំណត់ ហើយថ្នាក់ឈប់ធ្វើសកម្មភាពប្រទូសរ៉ាយ និងពង្រាយទ័ពឬចលនាឬធ្វើអំពើណាមួយដែលនឹងពង្រីកទឹកដីដែល ខ្លួនគ្រប់គ្រង ឬដែលអាចនាំទៅដល់ការប្រយុទ្ធគ្នាឡើងវិញនោះ ។

# មាត្រា ២

## ប្រព័ន្ធទំនាក់ទំនងនៃក្រុមការងារយោធាចំរុះ

ក្រុមការងារយោធាចំរុះមួយ នឹងត្រូវបានរៀបចំឡើង ដើម្បីដោះស្រាយនូវរាល់បញ្ហាដែល អាចកើតមានឡើងក្នុង ការអនុវត្តន៍ការឈប់បាញ់គ្នា ។ ក្រុមនេះនឹងត្រូវដឹកនាំដោយនាយទាហានជាន់ខ្ពស់បំផុត របស់ អ.ស.ប នៅកម្ពុជា ឬ ដោយអ្នកតំណាងរបស់គាត់ ។ ភាគី នីមួយៗព្រមព្រៀងតាក់តាំង នូវនាយទាហានថ្នាក់ថ្នាក់ឧត្តមសេនីយ៍ត្រី ឬថ្នាក់ស្មើគ្នា ដើម្បីបំពេញការក្នុងក្រុមការងារយោធាចំរុះ។ សមាសភាព វិធីប្រតិបត្តិការនិងកន្លែងជួបជុំនៃក្រុមនេះ ត្រូវសំរេចកំណត់ឡើងដោយនាយទាហានជាន់ខ្ពស់បំផុត របស់ អ.ស.ប ដោយមានការពិគ្រោះជាមួយភាគីទាំងឡាយ ។ ការរៀបចំប្រព័ន្ធទាក់ទងដូចគ្នានេះ នឹងត្រូវបានធ្វើឡើងនៅកំរិតបញ្ជាការយោធាថ្នាក់ក្រោមៗដើម្បីដោះស្រាយបញ្ហាជាក់ស្តែងនៅនឹងកន្លែង ។

# មាត្រាទី ៣

## ការប្រមូលផ្តុំ ការស្នាក់នៅក្នុងបន្ទាយនៃកងកំលាំងរបស់បណ្តាភាគី និងការរក្សាទុកអាវុធ គ្រាប់រំសេវ និង សំភារៈរបស់គេ

១- ស្របទៅតាមប្រតិទិនប្រតិបត្តិការដូចបានលើកឡើងក្នុងកថាខ័ណ្ឌទី ៤ នៃមាត្រាទី ១ របស់ឧបសម្ព័ន្ធនេះ កងកំលាំងទាំងអស់នៃបណ្តាភាគី ដែលពុំទាន់បានទៅដល់តំបន់បន្ទាយស្នាក់នៅនោះ ត្រូវទៅជួបជុំគ្នានៅតំបន់ប្រមូលផ្តុំ ដែលបានកំណត់ទុកដែលនឹងត្រូវបានរៀបចំឡើងនិងដាក់អោយដំណើរការ ដោយផ្នែកយោធានៃអ៊ុនតាក់ ។ តំបន់ប្រមូលផ្តុំទាំងនេះត្រូវរៀបចំឡើងនិងអោយដំណើរការបាន មិនអោយតិចជាងមួយសប្តាហ៍ មុនការចាប់ផ្តើមដំណាក់កាលទី២ឡើយ ។ ភាគីទាំងអស់ព្រមព្រៀងថា នឹងរៀបចំអោយកងកំលាំងទាំងអស់របស់ខ្លួន ជាមួយនឹងអាវុធ គ្រាប់រំសេវ និងសំភារៈធ្វើដំណើរ ទៅកាន់តំបន់ប្រមូលផ្តុំក្នុងរយៈពេលពីរសប្តាហ៍ បន្ទាប់ពីការចាប់ផ្តើម ដំណាក់កាលទី ២ ទៅ ។ បុគ្គលិកទាំងអស់ដែល បានទៅដល់តំបន់ប្រមូលផ្តុំ បន្ទាប់មកនឹងត្រូវជូនដំណើរដោយបុគ្គលិកផ្នែក យោធារបស់អ៊ុនតាក់ ដោយនាំជាមួយទាំងអាវុធ គ្រាប់រំសេវ និងសំភារៈរបស់ខ្លួន ឆ្ពោះទៅតំបន់បន្ទាយដែលបានកំណត់ទុក ។ ភាគីទាំងអស់យល់ព្រមថា ធ្វើយ៉ាងណា អោយបុគ្គលិកដែលធ្វើដំណើរទៅកាន់តំបន់ប្រមូលផ្តុំ នឹងអាចធ្វើទៅបានដោយសុវត្ថិភាពទាំងស្រុងនិងដោយគ្មានការរំខាន ណាឡើយ ។

២- លើមូលដ្ឋាននៃពត៌មានដែលបានផ្តល់អោយស្របទៅតាមកថាខ័ណ្ឌទី ៣ នៃមាត្រាទី ១ នៃឧបសម្ព័ន្ធ នេះ អ៊ុនតាក់ ត្រូវបញ្ជាក់ប្រាប់ថា ដំណើរការប្រមូលផ្តុំ និងចូលក្នុងបន្ទាយបានរួចរាល់ចប់សព្វគ្រប់ហើយស្របតាមផែនការដែលបាន លើកឡើងនៅក្នុងកថាខ័ណ្ឌ ៤ នៃមាត្រាទី ១នៃឧបសម្ព័ន្ធនេះ។ អ៊ុនតាក់នឹងខិតខំបញ្ចប់ដំណើរការទាំងនេះក្នុងរយៈពេល ៤ សប្តាហ៍ចាប់ពីពេលចាប់ផ្តើមដំណាក់កាលទី ២ ។ នៅពេលដែលការប្រមូលផ្តុំនិងការចូលទៅកងកំលាំងទាំងអស់ទៅ

តំបន់បន្ទាយស្នាក់នៅ បានបញ្ចប់សព្វគ្រប់រៀងៗខ្លួនហើយ មេបញ្ជាការផ្នែកយោធារបស់ អ៊ុនតាក់ ត្រូវជូនពត៌មាននេះទៅ រាល់ភាគីទាំង៤។

៣- ភាគីទាំងឡាយយល់ព្រមថា នៅពេលដែលកងកំលាំងរបស់ខ្លួនចូលមកដល់កន្លែងបន្ទាយដែលបានកំណត់ទុកហើយ មេបញ្ជាការរបស់ខ្លួនត្រូវបញ្ជាដល់បុគ្គលិករបស់ខ្លួន អោយប្រគល់ជាបន្ទាន់នូវអាវុធ គ្រាប់រំសេវ និងសំភារៈទាំងអស់ទៅអ៊ុនតាក់ ដើម្បីគ្រប់គ្រងរក្សាទុក។

៤- អ៊ុនតាក់នឹងត្រួតពិនិត្យផ្ទៀងផ្ទាត់អាវុធ គ្រាប់រំសេវនិងសំភារៈដែលត្រូវប្រគល់អោយខ្លួន ដោយផ្ទៀងផ្ទាត់នឹងបញ្ជីដូចមាននិយាយក្នុងកថាខ័ណ្ឌ ៣-ខ- នៃមាត្រាទី ១ របស់ឧបសម្ព័ន្ធនេះ ដើម្បីពិនិត្យអោយឃើញថាអាវុធគ្រាប់រំសេវនិងសំភារៈទាំងអស់កាន់កាប់ដោយភាគីទាំងឡាយ បានត្រូវប្រគល់អោយអ៊ុនតាក់ គ្រប់គ្រងហើយ ។

## មាត្រា ៤
## ការផ្គត់ផ្គង់សម្ភារឡើងវិញដល់កងកំលាំងក្នុងរយៈពេលស្ថិតក្នុងបន្ទាយ

ផ្នែកយោធារបស់ អ៊ុនតាក់ ត្រូវត្រួតពិនិត្យការផ្គត់ផ្គង់សម្ភារ ឡើងវិញដល់កងកំលាំងទាំងអស់នៃបណ្តាភាគី ក្នុងរយៈពេលប្រមូលផ្តុំនិងដំណើរស្នាក់នៅក្នុងបន្ទាយ ។ ការផ្គត់ផ្គង់សម្ភារឡើងវិញទាំងនេះ គឺកំណត់តែចំពោះសំភារៈដែលគ្មានលក្ខណៈជាគ្រឿង ប្រហារជីវិត ដូចជាស្បៀង ទឹក សំលៀកបំពាក់ និងថ្នាំពេទ្យ ក៏ដូចជាការព្យាបាលជំងឺ ។

## មាត្រា ៥
## ការដោះស្រាយជាចុងក្រោយពីរឿងកងកំលាំងរបស់បណ្តាភាគី ព្រមទាំងអាវុធគ្រាប់រំសេវនិងសំភារៈ របស់គេ

១- ដើម្បីពង្រឹងទិសដៅនៃដំណោះស្រាយនយោបាយរួម បន្ថយគ្រោះថ្នាក់នៃការវិលត្រឡប់ទៅរកសង្គ្រាមឡើងវិញ ធ្វើអោយសភាពការណ៍សន្តិសុខមានស្ថិរភាពនិងកសាងជំនឿទុកចិត្តគ្នា នៅក្នុងចំណោមភាគីនៅក្នុងជំលោះនោះ ភាគីទាំងអស់សុខចិត្តយល់ព្រមអោយដំណើរការជាដំណាក់ និងតុល្យភាពនូវការរំសាយកងកំលាំងយោធារបស់ខ្លួនយ៉ាងតិច ៧០ ភាគរយ ។ ដំណើរការនេះនឹងត្រូវអនុវត្តស្របទៅនឹងផែនការលំអិតមួយ ដែលនឹងត្រូវរៀបចំដោយអ៊ុនតាក់ ដោយផ្អែកទៅលើពត៌មានដែលមានចែងក្នុងមាត្រា១ នៃឧបសម្ព័ន្ធនេះ និងដោយមានការពិគ្រោះគ្នាជាមួយ បណ្តាភាគី។ ដំណើរការរំសាយនេះត្រូវធ្វើអោយហើយសព្វគ្រប់ នៅមុនបញ្ចប់ការចុះបញ្ជីឈ្មោះសំរាប់ការបោះឆ្នោត និងនៅថ្ងៃណាមួយដែលត្រូវកំណត់ដោយតំណាងពិសេសរបស់លោកអគ្គលេខាធិការ ។

២- បណ្តាភាគីកម្ពុជា ប្តេជ្ញាចិត្តដោយខ្លួនឯង រំសាយកងកម្លាំងរបស់ខ្លួនទាំងអស់ដែលនៅសេសសល់មុន ឬក្រោយបន្តិចនៃ ការបោះឆ្នោតហើយបើក្នុងករណីណាការរំសាយទាំងស្រុងនោះ មិនអាចសំរេចបានទេ ត្រូវគោរពនិងប្រព្រឹត្ត

តាមនូវសេចក្តីសំរេចណា ដែលរដ្ឋាភិបាលថ្មីជាប់ឆ្នោត អនុវត្តយកកងកំលាំងទាំងនោះបញ្ចូលទៅក្នុង កងទ័ពជាតិថ្មីជាផ្នែក ឬទាំងស្រុង ស្របតាមមាត្រាទី ១២ នៃកិច្ចព្រមព្រៀងនេះ ។ ដោយយោងទៅនឹងកថាខ័ណ្ឌ ១ នៅពេលរំសាយកងកំលាំងចប់សព្វគ្រប់ហើយ ភាគីកម្ពុជា និងតំណាងពិសេសរបស់លោកអគ្គលេខាធិការត្រូវអនុវត្តការពិនិត្យដោយ ហ្មត់ចត់ទៀងទាត់នូវការដោះស្រាយចុងក្រោយនៃកងកំលាំងដែលនៅសេសសល់នៅក្នុងបន្ទាយ ក្នុងទិសដៅកំណត់យកចំណុចណាមួយខាងក្រោមដើម្បីអនុវត្ត :

ក- បើសិនជាភាគីទាំងឡាយយល់ព្រមបន្តធ្វើការរំសាយកងកំលាំងដែលនៅសេសសល់ក្នុងបន្ទាយទាំងស្រុង ឬមួយចំនួន ជាការប្រសើរនៅមុន ឬផ្ទុយទៅវិញ ក្រោយការបោះឆ្នោតបន្តិច តំណាងពិសេសនិងរៀបចំប្រតិទិនមួយសំរាប់ការងារនោះដោយពិគ្រោះជាមួយបណ្តាភាគី ។

ខ- បើសិនជាការរំសាយទាំងស្រុងនូវកងកំលាំងទាំងអស់ ដែលនៅសេសសល់មិនអាចប្រព្រឹត្តទៅបានមុន ឬ ក្រោយបន្តិចនៃការបោះឆ្នោតនោះទេ បណ្តាភាគីត្រូវអនុវត្តបាននូវការប្រគល់កងកំលាំងដែលនៅសេសសល់ទាំងអស់របស់ខ្លួនក្នុងបន្ទាយទៅអោយរដ្ឋាភិបាលថ្មីជាប់ឆ្នោតស្របតាមមាត្រា ១២ នៃកិច្ចព្រមព្រៀងនេះ ដើម្បីពិនិត្យបញ្ចូលក្នុងកងទ័ពជាតិថ្មីមួយ ។ ភាគីទាំងឡាយបន្តយល់ព្រមថា កងកំលាំងទាំងឡាយណាដែលមិនបញ្ចូលទៅក្នុងកងទ័ពជាតិថ្មីនោះ និងត្រូវរំសាយជាបន្ទាន់ ស្របតាមផែនការមួយដែលរៀបចំឡើងដោយតំណាងពិសេស ។ ស្តីពីដំណោះស្រាយចុងក្រោយនៃកងកំលាំង ដែលនៅសេសសល់និងអាវុធ គ្រាប់រំសេវ និងសំភារៈទាំងអស់ នៅពេលខ្លួនរៀបចំចេញពីកម្ពុជាអ៊ុនតាក់ ត្រូវរក្សាទុកនូវសិទ្ធិដែលចាំបាច់ ដើម្បីធានាការផ្ទេរដោយរលូនភ្លាមៗទៅរដ្ឋាភិបាលថ្មីជាប់ឆ្នោតនូវភារកិច្ចដែលខ្លួនបាន អនុវត្តក្នុងដំណាក់កាលអន្តរកាល ។

៣- ជាចាំបាច់ អ៊ុនតាក់និងជួយដល់កងកំលាំងដែលបានរំសាយមុនពេលបោះឆ្នោត អោយចូលទៅក្នុងជីវភាពស៊ីវិល ។

៤ ក- អ៊ុនតាក់និងបន្តត្រួតពិនិត្យ និងឃុំគ្រងអាវុធ គ្រាប់រំសេវ និងសំភារៈទាំងអស់របស់បណ្តាភាគី ក្នុងដំណាក់-កាលអន្តរកាល ។

ខ- នៅពេលដែលរំសាយកងកំលាំងនៅក្នុងបន្ទាយ ស្របតាមកថាខ័ណ្ឌ ១ ខាងលើនេះ អ៊ុនតាក់ត្រូវធ្វើការកាត់បន្ថយក្នុងពេលជាមួយគ្នានូវអាវុធ គ្រាប់រំសេវ និងសំភារៈដែលបានរក្សាទុកនៅកន្លែង ក្នុងតំបន់បន្ទាយ ។ ចំពោះកងកំលាំងដែលនៅសេសសល់ក្នុងតំបន់បន្ទាយ ការចូលទៅយកអាវុធ គ្រាប់រំសេវនិងសំភារៈរបស់ខ្លួនត្រូវតែផ្អែកទៅលើការអនុញ្ញាតច្បាស់លាស់ពីតំណាងពិសេសរបស់លោកអគ្គលេខាធិការ ។

គ- បើសិនជាពេលការរំសាយកងកំលាំងយោធាបន្តទៀត ដោយយោងតាមកថាខ័ណ្ឌ ២ "ក" ខាងលើ អ៊ុនតាក់និងធ្វើការកាត់បន្ថយតាមសមាមាត្រដូចគ្នានូវអាវុធ គ្រាប់រំសេវ និងសំភារៈដែលរក្សាទុកនៅកន្លែងក្នុងតំបន់បន្ទាយ ។

ឃ- ការដោះស្រាយចុងក្រោយនូវអាវុធ គ្រាប់រំសេវ និងសំភារៈទាំងអស់ និងត្រូវសំរេច កំណត់ដោយរដ្ឋាភិបាល ដែលកើតចេញពីការបោះឆ្នោត ដោយសេរី និងត្រឹមត្រូវ ស្របតាមមាត្រាទី ១២ នៃកិច្ចព្រមព្រៀងនេះ ។

## មាត្រា ៦
## ការពិនិត្យបញ្ជាក់អំពីការដកចេញពីកម្ពុជា
## និងការមិនត្រឡប់វិញនៃកងកំលាំងបរទេសគ្រប់ប្រភេទទាំងអស់

១- ក្នុងរយៈពេលមិនតិចជាងពីរសប្តាហ៍មុនពេលចាប់ផ្តើមដំណាក់កាលទី ២ នៃការឈប់បាញ់ គេត្រូវផ្តល់អោយ អ៊ុនតាក់នូវពត៌មានលំអិតជាលាយលក្ខណ៍អក្សរស្តីពីការដកកងកំលាំងបរទេស ។ ពត៌មាន ទាំងនេះត្រូវរួមមានចំណុចដូចតទៅនេះ :

ក- កំលាំងសរុប ការចាត់តាំងនិងការដាក់ពង្រាយនៃកងកំលាំងទាំងនេះ

ខ- បញ្ជីសរុបនៃគ្រឿងអាវុធ គ្រាប់រំសេវ និងសំភារៈដែលកងកំលាំងទាំងនេះ កាន់កាប់ និងកន្លែង ទីតាំងពិតប្រាកដនៃរបស់អស់ទាំងនោះ ។

គ- ផែនការដកថយចេញ " អនុវត្តហើយក្តី ឬ ដែលនឹងត្រូវអនុវត្ត " រួមទាំងផ្លូវដកថយចេញចំណុចឆ្លងព្រំដែន និងពេលវេលាចាកចេញពីកម្ពុជា ។

២- លើមូលដ្ឋាននៃពត៌មានដែលគេបានផ្តល់អោយស្របទៅតាមកថាខ័ណ្ឌទី ១ ខាងលើនេះ អ៊ុនតាក់នឹងធ្វើការស្រាវជ្រាវ និងស៊ើបអង្កេតតាមរបៀបដែលខ្លួនយល់ថាសមស្រប ។ ភាគីដែលបានផ្តល់ពត៌មានអោយត្រូវផ្តល់បុគ្គលិករបស់ខ្លួន បញ្ជូនអមដំណើរអ្នកធ្វើការស្រាវជ្រាវអង្កេតរបស់អ៊ុនតាក់ ។

៣- នៅពេលមានសេចក្តីបញ្ជាក់ថា មានវត្តមានកងកំលាំងបរទេសណាមួយនោះ អ៊ុនតាក់នឹងដាក់ពង្រាយ បុគ្គលិករបស់ខ្លួនជាបន្ទាន់ទៅយកកងកំលាំងបរទេស ហើយអមដំណើរ [illegible] នោះរហូតទាល់តែដកចេញផុតពីទឹកដីកម្ពុជា ។ អ៊ុនតាក់ក៏នឹងបង្កើតកន្លែងត្រួតពិនិត្យនៅតាមផ្លូវដក កងកម្លាំង ចំណុចឆ្លងព្រំដែននិងអាកាសយានដ្ឋាន ដើម្បីពិនិត្យបញ្ជាក់ ពីការដកចេញ និងធានាថាកងកំលាំងបរទេសគ្រប់ប្រភេទមិនវិលត្រឡប់មកវិញទេ ។

៤- ក្រុមការងារយោធាចំរុះដែលមានចែងនៅក្នុងមាត្រា ២ នៃឧបសម្ព័ន្ធនេះត្រូវជួយ អ៊ុន តាក់ ក្នុងការអនុវត្តនូវការកិច្ចដូចចែងខាងលើនេះ ។

## មាត្រា ៧

## ការបញ្ឈប់ជំនួយផ្នែកយោធាពីខាងក្រៅដល់ភាគីកម្ពុជាទាំងអស់

១- ភាគីទាំងអស់សន្យាថា ចាប់តាំងពីពេលចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះទៅ ឈប់ទទួលយកឬស្វែងរកជំនួយយោធាពីក្រៅណាទាំងអស់ រួមទាំងអាវុធ គ្រាប់រំសេវ និងសំភារៈសឹកមកពីប្រភពខាងក្រៅ ។

២- ហត្ថលេខីទាំងឡាយដែលទឹកដីប្រទេសខ្លួនស្ថិតជាប់នឹងប្រទេសកម្ពុជា គឺរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ រាជាណាចក្រថៃឡង់ និងសាធារណរដ្ឋសង្គមនិយមវៀតណាម សន្យាថានឹង :

ក- ហាមឃាត់មិនអោយទឹកដីនៃប្រទេសរៀងខ្លួន រាប់ទាំងដែនដី ដែនសមុទ្រ និងដែនអាកាស ត្រូវគេប្រើប្រាស់ក្នុងបំណងផ្តល់ជំនួយយោធាដោយផ្ទាល់ឬប្រយោលដល់ភាគីកម្ពុជាណាមួយឡើយ ។ ការផ្តល់ សម្ភារជាថ្មីដូចជា ស្បៀង ទឹក សំលៀកបំពាក់ និងសំភារៈពេទ្យ តាមរយៈប្រទេសទាំងនោះនឹងត្រូវបានអនុញ្ញាត ប៉ុន្តែត្រូវជាកម្មវត្ថុនៃការពិនិត្យមើលរបស់ អ៊ុនតាក់ ពេលមកដល់កម្ពុជា ដោយ មិនធ្វើអោយប៉ះពាល់ដល់ប្រការនៃអនុកថាខណ្ឌ " ខ " ខាងក្រោមនេះ ។

ខ- បញ្ជាក់ជាលាយលក្ខណ៍អក្សរ ទៅដល់មេបញ្ជាការផ្នែកយោធារបស់អ៊ុនតាក់ មិនអោយលើស [illegible] សប្តាហ៍បន្ទាប់ពីចាប់ផ្តើមដំណាក់កាលទី ២ នៃការឈប់បាញ់គ្នា ថាគ្មាន[illegible] អាវុធ គ្រាប់រំសេវ ឬសំភារៈ[illegible] ភាគីកម្ពុជាណាមួយមានវត្តមាននៅក្នុងទឹកដីរបស់ខ្លួនទៀត ។

គ- ទទួលយកមន្រ្តីទំនាក់ទំនងរបស់ អ៊ុនតាក់ ប្រចាំនៅក្នុងរដ្ឋធានីរៀងខ្លួន និងចាត់តាំង[illegible] ដែលមានឋានន្តរស័ក្តិជាវរសេនីយ៍ឯកឬឋានៈប្រហាក់ប្រហែលគ្នានេះ មិនអោយហួសពី ៤ [illegible] បន្ទាប់ពីចាប់ផ្តើមដំណាក់កាលទី ២ នៃការឈប់បាញ់គ្នា ដើម្បីជួយអ៊ុនតាក់ ក្នុងការស៊ើបអង្កេត[illegible] ដោយគោរពយ៉ាងត្រឹមត្រូវចំពោះអធិបតេយ្យភាពរបស់ប្រទេសរៀងខ្លួន ថាកំពុងមានសកម្មភាពកើតឡើងនៅក្នុងទឹកដីរបស់ខ្លួន ដែលផ្ទុយនឹងប្រការទាំងឡាយនៃដំណោះស្រាយនយោបាយនេះ ។

៣- ដើម្បីអោយអ៊ុនតាក់អាចតាមដានការបញ្ឈប់ជំនួយបរទេសទៅអោយភាគីកម្ពុជាទាំងអស់ បណ្តាភាគីព្រមព្រៀងថា បន្ទាប់ពីចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ គេនឹងផ្តល់ជូនដល់អ៊ុនតាក់ នូវពត៌មានដែលគេមានអំពីផ្លូវ និងមធ្យោបាយដែលអាវុធ គ្រាប់រំសេវ និងសំភារៈ យោធាបានផ្តល់ទៅអោយ ភាគីណាមួយកន្លងមក ។ បន្ទាប់ពីដំណាក់កាលទី ២ ការឈប់បាញ់គ្នាចាប់ផ្តើមភ្លាមនោះ អ៊ុនតាក់នឹងអនុវត្តវិធានការជាក់ស្តែងដូចតទៅ :

ក- បង្កើតកន្លែង ត្រួតពិនិត្យតាមផ្លូវ និងនៅកន្លែងជ្រើសរើសក្បែរចំនួនតាមបណ្តោយព្រំដែន ខាងកម្ពុជា និងនៅព្រលានយន្តហោះក្នុងប្រទេសកម្ពុជា

ខ- ឃ្លាំមើលតាមឆ្នេរសមុទ្រនិងតាមដងផ្លូវទឹកទាំងឡាយក្នុងប្រទេសកម្ពុជា

ឃ- រក្សាក្រុមចល័តនៅកន្លែងយុទ្ធសាស្ត្រ នៅក្នុងប្រទេសកម្ពុជា ដើម្បីឃ្លាំមើលនិងស៊ើបអង្កេត ការចោទប្រកាន់អំពីការផ្តល់អាវុធទៅឱ្យភាគីណាមួយ ។

## មាត្រា ៨
## កន្លែងលាក់អាវុធនិងសំភារៈយោធា

១- ដើម្បីធ្វើអោយសភាពការណ៍សន្តិសុខមានស្ថិរភាព កសាងជំនឿទុកចិត្ត និង បន្ថយការផ្តល់អាវុធនិងសំភារៈយោធាទូទាំងប្រទេសកម្ពុជា ភាគីនីមួយៗព្រមព្រៀងផ្តល់ជូនបញ្ជាការផ្នែកយោធារបស់អ៊ុនតាក់នូវពត៌មានទាំងឡាយដែលខ្លួនមានរាប់ទាំងផែនទីដែលមានចំនួនបញ្ជាក់ច្បាស់អំពីកន្លែងលាក់អាវុធ និងសំភារៈសឹកដែលគេដឹងឬដែលគេសង្ស័យនៅទូទាំង ប្រទេសកម្ពុជា អោយបានមុនកាលបរិច្ឆេទ ដែលកំណត់ដោយបញ្ជាការយោធារបស់ អ៊ុនតាក់នេះ ។

២- លើមូលដ្ឋានពត៌មានដែលបានទទួល ផ្នែកយោធារបស់ អ៊ុនតាក់ ក្រោយថ្ងៃដែលមានចែងនៅក្នុងកថាខណ្ឌ ១ ត្រូវតែងតាំងក្រុមពិនិត្យបញ្ជាក់ដើម្បីទៅស៊ើបអង្កេតតាមរបាយការណ៍នីមួយៗ និងបំផ្លាញកន្លែងលាក់អាវុធដែលបានរកឃើញ ។

## មាត្រា ៩
## គ្រឿងយុទ្ធភណ្ឌដែលមិនទាន់ផ្ទុះ

១- ក្រោយពេលមកដល់ប្រទេសកម្ពុជាភ្លាម ផ្នែកយោធារបស់ អ៊ុនតាក់ ជាជំហានដំបូងត្រូវធ្វើយ៉ាងណាអោយគូសចំណាំយ៉ាងច្បាស់លាស់រាល់ចំការមីន ដែលបានដឹងហើយ ។

២- ភាគីទាំងអស់ព្រមព្រៀងគ្នាថា ក្រោយពីការបញ្ចប់ដំណើរការប្រមូលផ្តុំ និង ដាក់ក្នុងឃ្លាំងហើយ ស្របតាមមាត្រាទី ៣ នៃឧបសម្ព័ន្ធនេះ ភាគីទាំងនេះនឹងរៀបចំអោយមានក្រុមដោះសំអាតមីន ដែលត្រូវចាកចេញពីតំបន់បន្ទាយស្នាក់នៅ ដោយនៅក្រោមការត្រួតពិនិត្យរបស់បុគ្គលិកយោធារបស់ អ៊ុនតាក់ ដើម្បីជួយអ៊ុនតាក់ដកហូតយកចេញ ឬ ក៏ធ្វើអោយលែងផ្ទុះ គ្រឿងយុទ្ធភណ្ឌទាំងឡាយដែលនៅសេសសល់ហើយមិនទាន់ផ្ទុះ ។ គ្រាប់មីន ឬ វត្ថុទាំងអស់នេះដែលមិនអាចយក ឬ ដោះយកចេញ ឬក៏ធ្វើអោយលែងផ្ទុះបាន នឹងត្រូវគូសចំណាំយ៉ាងច្បាស់តាមបែបផែនមួយដែលតាក់តែងឡើងដោយផ្នែកយោធារបស់ អ៊ុនតាក់ ។

៣- អ៊ុនតាក់ត្រូវ :

ក- ចាត់តាំងកម្មវិធីអប់រំសាធារណៈមួយ ដើម្បីអោយគេស្គាល់និងជៀសវាងគ្រឿងផ្ទុះទាំងឡាយនោះ ។

ខ- ហ្វឹកហ្វឺនអ្នកស្ម័គ្រចិត្តកម្ពុជាអោយបំផ្លាញចោលគ្រឿងយុទ្ធភណ្ឌដែលមិនទាន់ផ្ទុះទាំងនោះ ។

គ- បង្ហាត់ហ្វឹកហ្វឺនវិជ្ជាខាងការជួយសង្គ្រោះបន្ទាន់ដល់អ្នកស្ម័គ្រចិត្តកម្ពុជា ។

## មាត្រា ១០

## ការស៊ើបអង្កេតចំពោះការរំលោភទាំងឡាយ

១- ក្រោយពីការចាប់ផ្តើមដំណាក់កាលទី ២ នៅពេលបានទទួលពាក្យបណ្តឹង ឬក៏ពាក្យបណ្តឹងនាំមកពីភាគីណាមួយ ដែលទាក់ទងទៅនឹងករណីមិនគោរពអនុវត្តតាមប្រការណាមួយនៃឧបសម្ព័ន្ធនេះ ឬក៏ប្រការផ្សេងៗដែលពាក់ព័ន្ធ អ៊ុនតាក់ ត្រូវធ្វើការស៊ើបអង្កេតតាមរូបភាពណាមួយដែលខ្លួនយល់ថាសមស្រប ។ នៅពេលដែលការស៊ើបអង្កេតប្រព្រឹត្តទៅដើម្បីឆ្លើយតបចំពោះបណ្តឹងនាំរបស់ភាគីណាមួយ ភាគីនោះនឹងត្រូវស្នើសុំអោយផ្តល់បុគ្គលិករបស់ខ្លួនជួយដល់ការធ្វើការស៊ើបអង្កេតរបស់ អ៊ុនតាក់ ។ លទ្ធផលនៃការស៊ើបអង្កេតបែបនេះនឹងត្រូវបញ្ជូនដោយ អ៊ុនតាក់ ទៅបរាយភាគីដែលប្តឹងនាំ និង ភាគីដែលត្រូវគេប្តឹងនេះ ហើយបើចាំបាច់ទៅបរាយ ឧសអិនស៊ុ ។

២- អ៊ុនតាក់ ក៏នឹងធ្វើការស៊ើបអង្កេតដោយគំនិតផ្តួចផ្តើមខ្លួនឯងផ្ទាល់ដែរ ក្នុងករណីផ្សេងៗទៀត នៅពេលដែលខ្លួនមានហេតុផល និងជឿ ឬសង្ស័យថាការរំលោភលើឧបសម្ព័ន្ធនេះ ឬប្រការពាក់ព័ន្ធផ្សេងៗ ទៀតអាចកើតមាន ។

## មាត្រា ១១

## ការដោះលែងឈ្លើយសឹក

ផ្នែកយោធានៃអ៊ុនតាក់ នឹងជួយឧបត្ថម្ភដល់គណៈកម្មការកាកបាទក្រហមអន្តរជាតិតាមសំណូមពរ ក្នុងការបំពេញការកិច្ចរបស់អង្គការនេះទាក់ទងទៅនឹងការដោះលែងឈ្លើយសឹក ។

## មាត្រា ១២

## ការធ្វើមាតុភូមិនិវត្តន៍ និង ការតាំងទីលំនៅជាថ្មីនៃប្រជាជនកម្ពុជា ផ្លាស់ប្តូរទីកន្លែង

ផ្នែកយោធានៃអ៊ុនតាក់ នឹងជួយឧបត្ថម្ភតាមការចាំបាច់ដល់ការធ្វើមាតុភូមិនិវត្តន៍របស់ជនភៀសខ្លួន, និងជនផ្លាស់ប្តូរទីកន្លែងកម្ពុជា ដែលអនុវត្តទៅ ស្របនឹងមាត្រាទី ១៩ និង ២០ នៃកិច្ចព្រមព្រៀងនេះ ជាពិសេសការបោសសំអាតមីនចេញពីផ្លូវធ្វើមាតុភូមិនិវត្តន៍ និងបណ្ឌលទទួល និងតំបន់តាំងទីលំនៅថ្មី ព្រមទាំងការការពារបណ្ឌលទទួលជនភៀសខ្លួនផង ។

ឧបសម្ព័ន្ធទី ៣

..............

## ការបោះឆ្នោត

១- សភាធម្មនុញ្ញដែលមានលើកឡើងនៅក្នុងមាត្រាទី ១២ នៃកិច្ចព្រមព្រៀងត្រូវមានសមាជិកចំនួន ១២០ នាក់ ។ នៅក្នុងរយៈពេល ៣ ខែ ចាប់ពីពេលបោះឆ្នោត សភាធម្មនុញ្ញត្រូវបំពេញបញ្ចប់ភារកិច្ចរបស់ខ្លួនក្នុងការធ្វើសេចក្តីព្រាង ហើយអនុម័តរដ្ឋធម្មនុញ្ញថ្មីមួយរបស់កម្ពុជា និងប្រែក្លាយខ្លួនឯងបរាយទៅជាសភានីតិបញ្ញត្តិមួយដែលនឹងត្រូវបង្កើតរដ្ឋាភិបាលកម្ពុជាថ្មីមួយឡើង ។

២- ការបោះឆ្នោតដែលមានលើកឡើងនៅក្នុងមាត្រា ទី ១២ នៃកិច្ចព្រមព្រៀង ត្រូវប្រព្រឹត្តទៅ នៅទូទាំងប្រទេសកម្ពុជា ស្របតាមប្រព័ន្ធតំណាងសមាមាត្រតាមខេត្ត ដោយផ្អែកទៅលើបញ្ជីរាយនាមរបស់ បេក្ខជនដែលស្នើឡើងដោយបណ្តាគណៈបក្សនយោបាយ ។

៣- ជនជាតិកម្ពុជាទាំងអស់ រួមទាំងអ្នកដែលនៅពេលកិច្ចព្រមព្រៀងនេះ បានត្រូវចុះហត្ថលេខា គឺជាជនភៀសខ្លួន និងជាជនផ្លាស់ប្តូរទីកន្លែងកម្ពុជា ត្រូវមានសិទ្ធិ សេរីភាព និងឱកាសដូចៗគ្នា ដើម្បីចូលរួមក្នុងដំណើរការបោះឆ្នោត ។

៤- អ្នកទាំងឡាយណាដែលមានអាយុគ្រប់ដប់ប្រាំបីឆ្នាំ នៅក្នុងពេលចុះឈ្មោះបោះឆ្នោតឬក៏ទើបតែ ដល់អាយុ ១៨ ឆ្នាំ នៅក្នុងរយៈពេលនៃការចុះឈ្មោះបោះឆ្នោតហើយ ឬមួយបានកើតនៅក្នុងប្រទេសកម្ពុជា ឬមួយជា កូនរបស់អ្នកដែលបានកើតនៅក្នុងប្រទេសកម្ពុជា និងត្រូវមានសិទ្ធិបោះឆ្នោតក្នុងការបោះឆ្នោត។

៥- គេអាចបង្កើតគណៈបក្សនយោបាយ ដោយអ្នកដែលមានឈ្មោះបោះឆ្នោតមួយក្រុម មានមនុស្សចំនួន ៥០០០ នាក់ ។ កម្មវិធីនយោបាយរបស់គណៈបក្សត្រូវសមស្របជាមួយគោលការណ៍និងទិសដៅនៃកិច្ចព្រមព្រៀងស្តីអំពីដំណោះស្រាយនយោបាយរួមមួយ ។

៦- ដើម្បីឈរឈ្មោះឲ្យគេបោះឆ្នោតជាសមាជិកសភាធម្មនុញ្ញ បេក្ខជន ត្រូវបង្ហាញសមាជិកភាពនៃគណៈបក្សរបស់ខ្លួន ។ គណៈបក្សនយោបាយត្រូវបង្ហាញ បញ្ជីរាយនាមបេក្ខជនដែលឈរឈ្មោះសំរាប់ការបោះឆ្នោត ក្នុងនាមគណៈបក្សនោះ ហើយដែលត្រូវជាអ្នកមានសិទ្ធិបោះឆ្នោតដែលបានចុះឈ្មោះ ហើយ ។

៧- គណៈបក្សនយោបាយ ហើយនិងបេក្ខជនត្រូវមានឈ្មោះចុះក្នុងបញ្ជី ដើម្បីឈរឈ្មោះបោះឆ្នោត ។ អ៊ុនតាក់ ត្រូវបញ្ជាក់ថា គណៈបក្សនយោបាយនិងបេក្ខជនមានលក្ខណៈវិនិច្ឆ័យគ្រប់គ្រាន់ ដូចដែលបានកំណត់ហើយដើម្បីអោយគេអាចចូលរួមក្នុងការបោះឆ្នោតបាន ។ ការគោរពតាមយ៉ាងខ្ជាប់ខ្ជួនតាមបទបញ្ញាសីលធម៌មួយដែលកំណត់ឡើងដោយអ៊ុនតាក់ ដោយមាន ការពិគ្រោះយោបល់ជាមួយនិងអេសអិនស៊ី ផងនេះ ត្រូវធ្វើជាលក្ខខ័ណ្ឌមួយសំរាប់ការចូលរួមបោះឆ្នោតនេះ ។

៨- ការបោះឆ្នោត និងត្រូវធ្វើឡើងដោយសន្លឹកឆ្នោតជាសំងាត់ ដោយមានការរៀបចំសំរាប់ជួយដល់អ្នកណាដែលពិការ ភ្នែក មិនចេះអាន ឬមិនចេះសរសេរ ។

៩- សេរីភាពក្នុងការនិយាយស្តីក្នុងការប្រជុំគ្នា ហើយនិងក្នុងការធ្វើដំណើរ ត្រូវបានគោរពទាំងស្រុង ។ រាល់ គណៈបក្សនយោបាយដែលបានចុះឈ្មោះហើយ អាចប្រើប្រាស់ប្រព័ន្ធ [illegible] ការត្រឹមត្រូវនូវបណ្តាញឃោសនា បហារ សារពត៌មាន ទូរទស្សន៍ ហើយនិងវិទ្យុផង ។

## ឧបសម្ព័ន្ធទី ៤

# ការធ្វើមាតុភូមិនិវត្តន៍នៃជនភៀសខ្លួននិងជនផ្លាស់ប្តូរទីកន្លែងកម្ពុជា

## ភាគទី ១

### សេចក្តីផ្តើម

១- ជាភាគមួយនៃដំណោះស្រាយនយោបាយរួមនោះ ចាំបាច់ត្រូវផ្តល់ជំនួយឧបត្ថម្ភគ្រប់បែបយ៉ាងដល់ជនភៀសខ្លួន និងជនផ្លាស់ប្តូរទីកន្លែងកម្ពុជា ក៏ដូចជាដល់បណ្តាប្រទេសដែលផ្តល់ជំរកបណ្តោះអាសន្ន និងប្រទេសជាប្រភពដើមនៃជនភៀសខ្លួន ដើម្បីសំរួលដល់ការវិលត្រឡប់ដោយស្ម័គ្រចិត្តដោយសន្តិវិធីនិងការរៀបរៀងរបស់ជនភៀសខ្លួន និងជនផ្លាស់ប្តូរទីកន្លែង កម្ពុជាគ្រប់រូប ។ គេក៏ត្រូវធានាផងដែរ ថានឹងមិនមានបញ្ហាសេសសល់ណាមួយឡើយ សំរាប់ប្រទេសដែលផ្តល់ជំរកបណ្តោះអាសន្ននោះ ។ ប្រទេសជាប្រភពដើមនៃជនភៀសខ្លួន ដោយមានការទទួលខុសត្រូវចំពោះប្រជាជនរបស់ខ្លួនផ្ទាល់ ត្រូវទទួលយកការវិលត្រឡប់របស់ពួកគេនៅពេលណាមានលក្ខណៈអំណោយផលហើយនោះ ។

## ភាគទី ២

### បណ្តាលក្ខណៈដែលសំរួលអោយការវិលត្រឡប់នៃជនភៀសខ្លួន និងជនផ្លាស់ប្តូរទីកន្លែង

២- ការកសាងប្រជាជាតិកម្ពុជាឡើងវិញ តំរូវអោយគេគ្រប់គ្រងប្រើប្រាស់រាល់ ធនធានខាងកំលាំងមនុស្ស និងធម្មជាតិទាំងអស់របស់ប្រទេសនេះ ។ ដើម្បីសំរេចគោលបំណងនេះ ការវិលត្រឡប់ទៅកាន់ទីកន្លែងដែលជនជាតិកម្ពុជាជ្រើសរើសដោយខ្លួនឯងពេលវិលពីទីជំរកបណ្តោះអាសន្នរបស់ពួកគេនិងពីទីកន្លែងដទៃទៀតនៅក្រៅប្រទេសដែលជាដើមកំណើតរបស់ពួកគេនោះ គឺជាការរួមវិភាគទានមួយដ៏សំខាន់ ។

៣- គេត្រូវខិតខំប្រឹងប្រែងគ្រប់បែបយ៉ាងដើម្បីធានាថា លក្ខណៈសម្បត្តិដែលបាននាំអោយការជនភៀសខ្លួន និងជនផ្លាស់ប្តូរ ទីកន្លែងកម្ពុជាមួយចំនួនធំបានទៅស្វែងរកទីជំរកនៅក្នុងបណ្តាប្រទេសដទៃទៀតនោះ មិនកើតមានសាជាថ្មីឡើយ ។ ទោះជាយ៉ាងណាក៏ដោយជនភៀសខ្លួន និងជនផ្លាស់ប្តូរទីកន្លែងកម្ពុជាណាៗដែលមានបំណងនឹងអាចវិលត្រឡប់ដោយភ្លាមៗខ្លួនឯងទៅកាន់មាតុភូមិរបស់ពួកគេវិញ ។

៤- ត្រូវមានការគោរពទាំងស្រុងចំពោះសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានរបស់ជនកម្ពុជាគ្រប់រូប រួមទាំងសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានរបស់ជនភៀសខ្លួននិងជនផ្លាស់ប្តូរទីកន្លែងដែលបានវិលត្រឡប់ទៅកាន់មាតុភូមិវិញផង ដោយទទួលស្គាល់ដល់សិទ្ធិរបស់ពួកគេដើម្បីរស់នៅដោយសន្តិភាពនិងសន្តិសុខដោយគ្មានការសំឡុតគំរាមកំហែងឬបង្ខិតបង្ខំទាំងអស់

សិទ្ធិទាំងនោះ និងរួមមានក្នុងចំណោមសិទ្ធិដទៃទៀត សេរីភាពក្នុងការធ្វើដំណើរនៅក្នុងប្រទេស កម្ពុជា សិទ្ធិជ្រើសរើសលំនៅ-ដ្ឋាន និងប្រកបមុខរបរការងារ ហើយនិងសិទ្ធិក្នុងការមានកម្មសិទ្ធិ ។

៥- ស្របទៅតាមដំណោះស្រាយនយោបាយរួម គេត្រូវខិតខំប្រឹងប្រែងគ្រប់បែបយ៉ាងដើម្បីបង្កើតក្នុងពេលជាមួយគ្នានៅក្នុងប្រទេសកម្ពុជានូវលក្ខខណ្ឌសន្តិសុខខាងនយោបាយ សេដ្ឋកិច្ចនិងសង្គមដែលសំរួលដល់ការវិលត្រឡប់ ដំណាក់ ចូលមករស់នៅវិញដោយសុខដុមរមនា នៃជនភៀសខ្លួន និងជនផ្លាស់ប្តូរទីកន្លែងកម្ពុជា ។

៦- ដើម្បីធានាអោយជនភៀសខ្លួន និងជនផ្លាស់ប្តូរទីកន្លែងកម្ពុជា បានចូលរួមក្នុងការបោះឆ្នោត ការធ្វើមាតុភូមិនិវត្តន៍ដោយទ្រង់ទ្រាយធំ ត្រូវតែចាប់ផ្តើមនិងបញ្ចប់អោយបានឆាប់រហ័សបំផុតតាមដែលអាចធ្វើបានដោយគិតគូរទៅដល់រាល់កត្តានយោបាយ មនុស្សធម៌ ភស្តុភារ ដឹកជញ្ជូន បច្ចេកទេស សង្គមកិច្ច សេដ្ឋកិច្ច ដែលពាក់ព័ន្ធ និងដោយរួមសហប្រតិបត្តិការជាមួយ និងក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ។

៧- ការធ្វើមាតុភូមិនិវត្តន៍នៃជនភៀសខ្លួន និងជនផ្លាស់ប្តូរទីកន្លែងកម្ពុជាត្រូវធ្វើឡើងដោយស្ម័គ្រចិត្ត ហើយការសំរេចចិត្តរបស់ពួកគេ ត្រូវធ្វើឡើងលើការដឹងច្បាស់នូវស្ថានភាពការណ៍ជាក់ស្តែង ។ ការជ្រើសរើសទីដៅនៅខាងក្នុងប្រទេសកម្ពុជា គប្បីជាសិទ្ធិជ្រើសរើសរបស់បុគ្គលម្នាក់ៗ ។ គេត្រូវរក្សាការឯកភាពរបស់គ្រួសារនីមួយៗ ។

# ភាគទី ៣
## កត្តាប្រតិបត្តិការ

៨- ស្របនឹងការគោរពចំពោះគោលការណ៍នៃអធិបតេយ្យភាពជាតិ ក្នុងប្រទេសដែលបានផ្តល់ជំរកបណ្តោះអាសន្ន និងប្រទេសជាប្រភពដើម ហើយដោយមានសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយប្រទេសដែលបានផ្តល់ជំរកបណ្តោះអាសន្ន និងប្រទេសជាប្រភពដើមផង គេត្រូវធានាអោយឧត្តមស្នងការសហប្រជាជាតិសំរាប់ជនភៀសខ្លួន គណៈកម្មា-ធិការកាកបាទក្រហមអន្តរជាតិ ព្រមទាំងអង្គការអន្តរជាតិដទៃទៀតដែលពាក់ព័ន្ធ បានជួបប្រាស្រ័យយ៉ាងពេញលេញជាមួយជនភៀសខ្លួន និងជនផ្លាស់ប្តូរទីកន្លែងកម្ពុជាទាំងអស់ ដើម្បីអោយបេសកម្មនានារបស់អង្គការទាំងនោះធ្វើការជំរឿនប្រជាជនស្វែងរកញាតិគ្រួសារ ផ្តល់ជំនួយសង្គ្រោះផ្នែកពេទ្យ ចែកចាយស្បៀងអាហារ ព្រមទាំងធ្វើសកម្មភាពផ្សេងៗទៀត ដែលចាំបាច់បំផុតដល់ ការបំពេញការកិច្ច និងការទទួលខុសត្រូវ ខាងផ្នែកប្រតិបត្តិការរបស់ពួកគេ ។ គេត្រូវអនុញ្ញាតអោយមានការជួបប្រាស្រ័យទាក់ទងបែបនេះផងដែរ នៅក្នុងប្រទេសកម្ពុជា ដើម្បីអោយបេសកម្មអង្គការអន្តរជាតិដែលពាក់ព័ន្ធអាចអនុវត្តការកិច្ចទទួលខុសត្រូវជាធម្មតារបស់គេខាងការតាមដានក៏ដូចខាងប្រតិបត្តិការ ។

៩- នៅក្នុងក្របខ័ណ្ឌនៃដំណោះស្រាយនយោបាយរួម ភាគីហត្ថលេខីធ្វើការកត់សំគាល់ដោយសេចក្តីពេញចិត្តថា លោកអគ្គលេខាធិការនៃអង្គការសហប្រជាជាតិបានប្រគល់អោយឧត្តមស្នងការប្រចាំអង្គការសហប្រជាជាតិសំរាប់ជនភៀសខ្លួន UNHCR នូវតួនាទីដឹកនាំនិងសំរបសំរួលក្នុងបេសកម្មអង្គការអន្តររដ្ឋាភិបាល ដែលជួយឧបត្ថម្ភដល់ការធ្វើមាតុភូមិនិវត្តន៍

ឧបត្ថម្ភជំនួយសង្គ្រោះដល់ជនភៀសខ្លួននិងជនផ្លាស់ទីកន្លែងកម្ពុជា ។ បណ្ដាហត្ថលេខីគិតថា អង្គការមិនមែនរដ្ឋាភិបាលដទៃទៀតនិងធ្វើការសំរបសំរួលការងាររបស់ខ្លួនអោយបានស្របគ្នាជាមួយ UNHCR សំរាប់ជនភៀសខ្លួននិងជនផ្លាស់ទីកន្លែងកម្ពុជា ។

១០ - ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ រដ្ឋាភិបាល នៃបណ្ដាប្រទេសដែលជនភៀសខ្លួននិងជនផ្លាស់ទីកន្លែងកម្ពុជា បានជ្រកកោនបណ្ដោះអាសន្ន ព្រមទាំងបណ្ដាប្រទេសដែលរួមចំណែកដល់កិច្ចប្រឹងប្រែងក្នុងការធ្វើមាតុភូមិនិវត្តន៍និងការចូលរួមរស់នៅវិញ និងការបំពេញការងារយ៉ាងជិតស្និទ្ធ ហើយជួយសំរួលដល់ការធ្វើមាតុភូមិនិវត្តន៍នៃអ្នកដែលវិលត្រឡប់វិញនេះ ។ អង្គការ[illegible]ad-hoc ឬមួយត្រូវបង្កើតឡើងសំរាប់រយៈពេលមួយជាក់លាក់ ដើម្បីគោលដៅនេះ ។ ឧត្តមស្នងការអង្គការសហប្រជាជាតិសំរាប់ជនភៀសខ្លួន គណៈកម្មការកាកបាទក្រហមអន្តរជាតិ ព្រមទាំងអង្គការអន្តរជាតិដែលសមស្របដទៃទៀតក៏ដូចជាមិត្តទាក់ទង និងត្រូវអញ្ជើញអោយចូលរួមជាសមាជិកពេញសិទ្ធិ ។

១១- ជំនួយឧបត្ថម្ភសំរាប់រយៈពេលខ្លីដល់ការធ្វើមាតុភូមិនិវត្តន៍ ហើយដោយមានការតាមដាន ដ៏សមស្របផងនោះ ត្រូវផ្តល់អោយដោយមិនបង្អង់ដើម្បីជួយអោយបណ្ដាគ្រួសារ និងបុគ្គលដែលវិលត្រឡប់មកកម្ពុជាវិញ អាចកសាងជីវភាពរស់នៅរបស់គេបានដោយសុខដុមរមនានៅក្នុងសង្គមរបស់ខ្លួន ។ វិធានការជាបណ្ដោះអាសន្នទាំងនេះនិងត្រូវកាត់បន្ថយជាបណ្ដើរៗ ហើយនិងជំនួសវិញសំរាប់រយៈពេលវែងដោយកម្មវិធីកសាងឡើងវិញ ។

១២- អ្នកដែលទទួលខុសត្រូវចំពោះការចាត់ចែង រៀបចំនិងពិនិត្យមើលប្រតិបត្តិការនៃការធ្វើមាតុភូមិនិវត្តន៍ ចាំបាច់ត្រូវធានាថា លក្ខណៈសម្បត្តិសន្តិសុខសំរាប់ការតាំងទីលំនៅរបស់ជនភៀសខ្លួន ហើយនិងជនផ្លាស់ទីកន្លែង ត្រូវបានរៀបចំហើយ ។ នៅក្នុងន័យនេះ ជាការចាំបាច់បំផុតដែលត្រូវកំណត់អោយបានហើយ ច្រកឆ្លងកាត់ព្រំដែន និងផ្លូវធ្វើដំណើរសមស្រប ដោយត្រូវបោសសំអាតមីននិងគ្រោះថ្នាក់ផ្សេងៗ ។

១៣- សហគមន៍អន្តរជាតិគួរតែផ្តល់ធនធានដោយសមស្របចំពោះតំរូវការផ្គត់ផ្គង់ហិរញ្ញវត្ថុសំរាប់ កិច្ចប្រតិបត្តិការធ្វើមាតុភូមិនិវត្តន៍ ។

# ឧបសម្ព័ន្ធទី ៥

## បណ្តាគោលការណ៍សំរាប់រដ្ឋធម្មនុញ្ញថ្មីមួយរបស់កម្ពុជា

១- រដ្ឋធម្មនុញ្ញ គឺជាច្បាប់កំពូលរបស់ប្រទេស ។ គេអាចធ្វើការកែប្រែរដ្ឋធម្មនុញ្ញនេះបានលុះត្រាតែគោរពរបៀបរបបជាក់លាក់ប្រយោលទាក់ទងដល់ ការយល់ព្រមពីអង្គការនីតិបញ្ញត្តិ ការធ្វើប្រជាមតិ ឬក៏ដោយវិធីទាំងពីរនេះតែម្តង ។

២- ប្រវត្តិសាស្ត្រថ្មីៗ ក្រោយរបបសោកនាដកម្មនៅកម្ពុជា ទាមទារអោយមានវិធានការពិសេស ដើម្បី ធានាការការពារសិទ្ធិមនុស្ស ។ ហេតុដូច្នេះរដ្ឋធម្មនុញ្ញត្រូវមានសេចក្តីថ្លែងការណ៍មួយអំពី សិទ្ធិជាមូលដ្ឋាន នៅក្នុងនោះមានសិទ្ធិក្នុងការមានជីវិតរស់នៅ សេរីភាពរបស់បុគ្គល សន្តិសុខ សេរីភាព ក្នុងការធ្វើដំណើរ សេរីភាពក្នុងជំនឿសាសនា របបប្រជុំគ្នានិងបង្កើតសមាគម រួមមានគណបក្សនយោបាយ និងសហជីព ដំណើរការនីតិវិធីត្រឹមត្រូវ និងភាពស្មើគ្នាចំពោះមុខច្បាប់ ការការពារកុំអោយមាន ការដកហូតកម្មសិទ្ធិដោយវិធីផ្តាច់ការ ឬការដកហូតកម្មសិទ្ធិឯកជនដោយគ្មានការសងជំងឺចិត្តដ៏ត្រឹមត្រូវ និងសេរីភាព ដោយគ្មានការប្រកាន់រើសអើងពូជសាសន៍ ជនជាតិ ជំនឿសាសនា ឬគំនិតនយោបាយ ។ រដ្ឋធម្មនុញ្ញត្រូវហាមឃាត់ [illegible] ។ សេចក្តីប្រកាសត្រូវស្របទៅនឹងប្រភពទាំងឡាយនៃសេចក្តីប្រកាសជាសកលអំពីសិទ្ធិមនុស្ស ព្រមទាំងកិច្ចព្រមព្រៀងអន្តរជាតិដទៃទៀត ដែលពាក់ព័ន្ធ ។ បុគ្គលដែលត្រូវរំលោភបំពានលើសិទ្ធិ ត្រូវទៅតុលាការដើម្បីកាត់សេចក្តី និងធ្វើអោយគេគោរពសិទ្ធិទាំងអស់នេះ ។

៣- រដ្ឋធម្មនុញ្ញត្រូវប្រកាសអំពីលក្ខន្តិកៈប្រទេសកម្ពុជា ជាប្រទេសអធិបតេយ្យ ឯករាជ្យ និងអព្យាក្រឹតភាព និងអំពីឯកភាពជាតិ របស់ប្រជាជនកម្ពុជា ។

៤- រដ្ឋធម្មនុញ្ញត្រូវប្រកាសថា កម្ពុជានឹងអនុវត្តប្រព័ន្ធប្រជាធិបតេយ្យសេរី ដោយឈរលើមូលដ្ឋានពហុបក្ស ។ រដ្ឋធម្មនុញ្ញត្រូវកំណត់អោយមានការបោះឆ្នោតដ៏ត្រឹមត្រូវ និងតាមកាលវេលា ។ រដ្ឋធម្មនុញ្ញត្រូវអនុញ្ញាតសិទ្ធិសំរាប់បោះឆ្នោត និងឈរឈ្មោះអោយគេបោះឆ្នោតតាមរបៀបបោះឆ្នោតជាសកល និងស្មើភាព ។ រដ្ឋធម្មនុញ្ញត្រូវអនុញ្ញាតអោយមានការបោះឆ្នោតដោយសម្ងាត់ ដោយតំរូវអោយទំរង់បែបបទនៃការបោះឆ្នោត ត្រូវផ្តល់ឱកាសគ្រប់គ្រាន់ និងសេរី ដើម្បីរៀបចំ និងចូលរួមក្នុងដំណើរការបោះឆ្នោត ។

៥- ត្រូវបង្កើតអង្គការតុលាការមួយឯករាជ្យ ដែលត្រូវមានអំណាចដាក់អោយអនុវត្តនូវបណ្តាសិទ្ធិដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។

៦- រដ្ឋធម្មនុញ្ញត្រូវអនុម័តដោយសំលេងភាគច្រើនពីរភាគបីនៃសមាជិករបស់សភាធម្មនុញ្ញ ។

# I. កិច្ចព្រមព្រៀងដែលទាក់ទងទៅនឹងអធិបតេយ្យភាព ឯករាជ្យ បូរណភាព និងភាពមិនអាចរំលោភបាន នៃដែនដី អព្យាក្រឹតភាពនិងឯកភាពជាតិកម្ពុជា

អូស្ត្រាលី - ប្រ៊ុយណេដារូសាឡាម - កម្ពុជា - កាណាដា - សាធារណរដ្ឋប្រជាមានិតចិន - សាធារណរដ្ឋបារាំង - សាធារណរដ្ឋឥណ្ឌា - សាធារណរដ្ឋឥណ្ឌូណេស៊ី - ជប៉ុន - សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ - ម៉ាឡេស៊ី - សាធារណរដ្ឋហ្វីលីពីន - សាធារណរដ្ឋសិង្ហបុរី - រាជាណាចក្រថៃឡង់ - សហភាពសាធារណរដ្ឋសង្គមនិយមសូវៀត - រាជាណាចក្ររួមអង់គ្លេស និងអៀរឡង់ខាងជើង - សហរដ្ឋអាមេរិក - សាធារណរដ្ឋសង្គមនិយមវៀតណាម និងសាធារណរដ្ឋសហព័ន្ធសង្គមនិយមយូហ្គោស្លាវី ។

ដោយមានវត្តមានរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ

ដោយជឿជាក់ថា ដំណោះស្រាយនយោបាយរួមមួយសំរាប់កម្ពុជាគឺជាការចាំបាច់សំរាប់គោលដៅយូរអង្វែងនៃការរក្សាសន្តិភាពនិងសន្តិសុខនៅតំបន់អាស៊ីអាគ្នេយ៍ ។

ដោយរំលឹកឡើងវិញ នូវកាតព្វកិច្ចរបស់ខ្លួន ស្របតាមធម្មនុញ្ញអង្គការសហប្រជាជាតិនិងវិធានបញ្ញត្តិនៃច្បាប់អន្តរជាតិដទៃទៀត ។

ដោយដាក់ទុកថា ការគោរពជាពេញលេញនូវគោលការណ៍មិនជ្រៀតជ្រែក និងមិនអន្តរាគមន៍ចូលកិច្ចការផ្ទៃក្នុង និងកិច្ចការក្រៅប្រទេសរបស់បណ្តារដ្ឋ គឺការសំខាន់បំផុតសំរាប់ថែរក្សាសន្តិភាព និងសន្តិសុខអន្តរជាតិ ។

ដោយអះអាងឡើងវិញ នូវសិទ្ធិមិនអាចកាត់ផ្តាច់បានរបស់បណ្តារដ្ឋដើម្បីជ្រើសរើសដោយសេរីនូវប្រព័ន្ធនយោបាយ សេដ្ឋកិច្ច វប្បធម៌ និងសង្គមរបស់ខ្លួនស្របតាមគោលបំណងរបស់ប្រជាជនខ្លួន ដោយគ្មានការជ្រៀតជ្រែក វិទ្ធង្សនាការបង្ខិតបង្ខំ ឬគំរាមកំហែងពីខាងក្រៅទោះតាមរូបភាពបែបណាក៏ដោយ ។

ដោយផ្តល់ជំរុញ ការគោរព និងអនុវត្តតាមសិទ្ធិមនុស្ស និង សេរីភាពជាមូលដ្ឋានស្របតាមធម្មនុញ្ញអង្គការសហប្រជា-ជាតិ និងច្បាប់អន្តរជាតិដែលទាក់ទិនដទៃៗទៀត ។

បានព្រមព្រៀងដូចតទៅ ៖

## មាត្រាទី ១

១- កម្ពុជាតាមរយៈឯកសារនេះសន្យាយ៉ាងឱឡារិកថា និងថែរក្សានិងការពារអធិបតេយ្យភាព ឯករាជ្យ បូរណភាព និងភាពមិនអាចរំលោភបាននៃដែនដី អព្យាក្រឹតភាព និងឯកភាពជាតិរបស់ខ្លួន ។ អព្យាក្រឹតភាពអចិន្ត្រៃយ៍របស់កម្ពុជា

និងត្រូវប្រកាស ហើយនិងចារឹកទុកនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា ដែលនឹងត្រូវអនុម័តក្រោយពីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវ ។

២- ដើម្បីសំរេចទិសដៅនេះ កម្ពុជាសន្យាថា:

ក- ជៀសវាងអំពើណាមួយ ដែលនាំទៅអោយប៉ះពាល់ដល់អធិបតេយ្យភាព ឯករាជ្យ បូរណភាព និងភាពមិនរំលោភបានលើដែនដីរបស់រដ្ឋដទៃ ។

ខ- ជៀសវាងចូលរួមក្នុងសម្ព័ន្ធភាពយោធា ឬបណ្តាកិច្ចព្រមព្រៀងយោធាណាមួយនឹងរដ្ឋដទៃៗទៀត ដែលមិនស្របតាមអព្យាក្រឹតភាពរបស់ខ្លួន តែប្រការនេះមិនរារាំងដល់សិទ្ធិរបស់កម្ពុជា ក្នុងការទទួលយកសំភារៈយោធា គ្រាប់រំសេវ និងជំនួយចាំបាច់ដែលអាចអោយកម្ពុជា អនុវត្តសិទ្ធិពេញលេញរបស់ខ្លួន ដើម្បីស្វ័យការពារ និងដើម្បីថែរក្សាច្បាប់ និងសណ្តាប់ធ្នាប់ ។

គ- ជៀសវាងជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់រដ្ឋដទៃ ៗ ទៀត ដោយផ្ទាល់ ឬ ដោយប្រយោល ទោះតាមរូបភាពណាក៏ដោយ ។

ឃ- បញ្ចប់សន្ធិសញ្ញា និងកិច្ចព្រមព្រៀងទាំងឡាយដែលមិនសមស្របទៅនឹងអធិបតេយ្យភាព ឯករាជ្យ បូរណភាព និងភាពមិនរំលោភបានលើដែនដី អព្យាក្រឹតភាព និងឯកភាពជាតិរបស់ខ្លួន ។

ង- ជៀសវាងគំរាមកំហែង ឬប្រើកំលាំងប្រឆាំងនឹងបូរណភាពដែនដីឬឯករាជ្យនយោបាយនៃរដ្ឋណាមួយ ឬដោយវិធានផ្សេងណាមួយ ដែលមិនស្របនឹងគោលបំណងរបស់អង្គការសហប្រជាជាតិ ។

ច- ដោះស្រាយរាល់ជំលោះជាមួយនឹងរដ្ឋដទៃទៀតដោយសន្តិវិធី ។

ឆ- ជៀសវាងប្រើដែនដីរបស់ខ្លួន ឬដែនដីរបស់រដ្ឋដទៃៗទៀត ដើម្បីធ្វើអោយប៉ះពាល់ដល់ អធិប-តេយ្យភាព ឯករាជ្យ បូរណភាព និងភាពមិនរំលោភបានលើដែនដីរបស់រដ្ឋដទៃៗទៀត ។

ជ- ជៀសវាងអនុញ្ញាតអោយមានវត្តមាន ឬដាក់ពង្រាយកងកំលាំងបរទេសរួមទាំងបុគ្គលិកយោធា ទោះក្នុងរូបភាពណាក៏ដោយនៅកម្ពុជា និងទប់ស្កាត់ការបង្កើត ឬរក្សាទុកមូលដ្ឋានយោធាបរទេស ចំណុចពង្រឹង ឬទីកន្លែងបញ្ជាការ នៅកម្ពុជាទៀយ លើកលែងតែមានការអនុញ្ញាតរបស់អង្គការសហប្រជាជាតិសំរាប់អនុវត្តនូវដំណោះស្រាយនយោបាយរួមមួយ ។

## មាត្រា ២

១- ភាគីនានាក្នុងកិច្ចព្រមព្រៀងនេះ តាមរយៈនេះ សន្យាយ៉ាងឧឡារិកថា ទទួលស្គាល់ និងគោរព គ្រប់បែបយ៉ាងនូវអធិបតេយ្យភាព ឯករាជ្យ បូរណភាពនិងភាពមិនរំលោភបានលើដែនដី អព្យាក្រឹតភាពនិងឯកភាពជាតិកម្ពុជា ។

២- ដើម្បីសំរេចទិសដៅនេះ ភាគីទាំងនេះសន្យាថា:

ក- ជៀសវាងចូលរួមក្នុងបក្សសម្ព័ន្ធយោធាណាមួយ ឬកិច្ចព្រមព្រៀងយោធាផ្សេងណាជាមួយ កម្ពុជាដែលមិនសមស្របនឹងអព្យាក្រឹតភាពរបស់កម្ពុជា តែប្រការទាំងនេះមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិកម្ពុជា ក្នុងការទទួលសំភារៈ យោធា អាវុធគ្រាប់រំសេវ និងជំនួយដែលចាំបាច់ ដើម្បីអោយកម្ពុជាប្រើប្រាស់នូវសិទ្ធិដ៏ពេញលេញរបស់ខ្លួនសំរាប់ការការពារខ្លួន និងដើម្បីរក្សាច្បាប់និងសណ្តាប់ធ្នាប់ ។

ខ- ជៀសវាងជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងកម្ពុជា ទោះក្នុងរូបភាពណាមួយក៏ដោយ ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ។

គ- ជៀសវាងគំរាមកំហែង ឬក៏ប្រើប្រាស់កំលាំងប្រឆាំងនឹងបូរណភាពដែនដី ឬក៏ឯករាជ្យខាងនយោបាយរបស់កម្ពុជា ក្នុងរូបភាពណាមួយដែលមិនសមស្រប នឹងគោលបំណងរបស់អង្គការសហប្រជាជាតិ ។

ឃ- ដោះស្រាយរាល់ជំលោះជាមួយកម្ពុជាដោយសន្តិវិធី ។

ង- ជៀសវាងប្រើប្រាស់ទឹកដីរបស់ខ្លួន ឬក៏ទឹកដីរបស់រដ្ឋដទៃទៀតដើម្បី ធ្វើអោយប៉ះពាល់ដល់អធិបតេយ្យភាព ឯករាជ្យ បូរណភាព និងភាពមិនរំលោភបានលើដែនដី អព្យាក្រឹតភាព និងឯកភាពជាតិរបស់កម្ពុជា។

ច- ជៀសវាងប្រើប្រាស់ទឹកដីកម្ពុជា ដើម្បីធ្វើអោយប៉ះពាល់ដល់អធិបតេយ្យភាព ឯករាជ្យ និងបូរណភាព និងភាពមិនរំលោភបានលើដែនដីរបស់រដ្ឋដទៃទៀត ។

ឆ- ជៀសវាងបញ្ចូល ឬតាំងមូលដ្ឋានកងកំលាំងបរទេស រួមទាំងបុគ្គលិកយោធានៅក្នុងកម្ពុជា ទោះក្នុងរូបភាពណាក៏ដោយ និងជៀសវាងបង្កើតឬក៏រក្សាទុកនូវមូលដ្ឋានយោធា ចំណុចបង្អែក ឬទីតាំងបញ្ជាការនៅក្នុងកម្ពុជា លើកលែង តែមានការអនុញ្ញាតពីការិយាល័យអង្គការសហប្រជាជាតិ សំរាប់ការអនុវត្តនូវដំណោះស្រាយនយោបាយរួមមួយ ។

មាត្រា ៣

១- មនុស្សទាំងអស់នៅកម្ពុជាត្រូវមានសិទ្ធិ និងសេរីភាពដែលបានចែងនៅក្នុងសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស និងច្បាប់អន្តរជាតិទាក់ទិននឹងសិទ្ធិមនុស្សឯទៀតៗ ។

២- ក្នុងគោលដៅនេះ

ក- កម្ពុជាសន្យាថា:

- ធានាគោរពនិងប្រតិបត្តិតាមសិទ្ធិមនុស្ស ហើយនិងសេរីភាពជាមូលដ្ឋាននៅកម្ពុជា

- គាំទ្រសិទ្ធិពលរដ្ឋកម្ពុជាទាំងអស់ ដើម្បីធ្វើសកម្មភាពដែលជំរុញ និងការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ។

- ចាត់វិធានការដ៏មានប្រសិទ្ធភាពដើម្បីធានាកុំអោយនយោបាយនិងអំពើប្រព្រឹត្តនៅក្នុងអតីតកាលវិលត្រឡប់មកវិញជាដាច់ខាត ។

- ចូលរួមក្នុងកិច្ចព្រមព្រៀងអន្តរជាតិ ស្តីពីសិទ្ធិមនុស្សដែលទាក់ទិន

២- ភាគីឯទៀតដែលចូលរួមក្នុងកិច្ចព្រមព្រៀងនេះ សន្យាជំរុញលើកទឹកចិត្តដល់ការគោរព និងអនុវត្តតាមសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាននៅកម្ពុជា ដូចដែលមានចែងក្នុងកិច្ចព្រមព្រៀងអន្តរជាតិ ដើម្បីជាពិសេសទប់ស្កាត់កុំអោយមានការរំលោភសិទ្ធិមនុស្សឡើងវិញ ។

៣- គណៈកម្មការអំពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ត្រូវបន្តតាមដានដោយជិតដិត ស្ថានការណ៍សិទ្ធិមនុស្សនៅកម្ពុជា រួមទាំងក្នុងករណីចាំបាច់តែងតាំងអ្នករាយការណ៍ពិសេសម្នាក់ ដែលត្រូវរាយការណ៍អំពីលទ្ធផលនៃការរកឃើញរបស់ខ្លួនជារៀងរាល់ឆ្នាំ ជូនទៅគណៈកម្មការ និងទៅមហាសន្និបាតអង្គការសហប្រជាជាតិ ។

## មាត្រា ៤

ភាគីដែលចុះកិច្ចព្រមព្រៀងនេះ អំពាវនាវដល់រដ្ឋនានាទៀតអោយទទួលស្គាល់និងគោរពគ្រប់បែបយ៉ាង ដល់អធិបតេយ្យភាព ឯករាជ្យ បូរណភាពនិងភាពមិនរំលោភបានលើដែនដី អព្យាក្រឹតភាព និងឯកភាពជាតិរបស់កម្ពុជា ហើយជៀសវាងធ្វើអំពើដែលមិនស្របនឹងគោលការណ៍ទាំងនោះ ឬដែលមិនស្របទៅនឹងប្រការដទៃទៀតនៃកិច្ចព្រមព្រៀងនេះ ។

## មាត្រា ៥

១- ក្នុងករណីមានការរំលោភ ឬការគំរាមកំហែងរំលោភលើអធិបតេយ្យភាព ឯករាជ្យ បូរណភាព និងភាពមិនរំលោភបានលើដែនដី អព្យាក្រឹតភាព ឬឯកភាពជាតិនៃកម្ពុជា ឬលើការប្តេជ្ញានានាដទៃទៀតដែលមានក្នុងកិច្ចព្រមព្រៀងនេះ បណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះធ្វើការពិគ្រោះជាបន្ទាន់ ដើម្បីអនុម័តយកវិធានការសមស្រប ដើម្បីធានាការគោរពដល់ការប្តេជ្ញាចិត្តទាំងនេះ និងដោះស្រាយរាល់ការរំលោភទាំងនោះ តាមមធ្យោបាយសន្តិវិធី ។

២- វិធានការបែបនេះ ក្នុងចំណោមវិធានការផ្សេងទៀត អាចរួមមានការរាយការណ៍ទៅក្រុមប្រឹក្សាសន្តិសុខ អង្គការសហប្រជាជាតិ ឬប្រើប្រាស់មធ្យោបាយដោះស្រាយនូវវិវាទដោយសន្តិវិធី យោងទៅតាមមាត្រា ៣៣ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ ។

៣- បណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះ ក៏អាចសុំការឧបត្ថម្ភពីសហប្រធាននៃសន្និសីទប៉ារីសស្តីពីកម្ពុជាដែរ ។

៤- ក្នុងករណីមានការរំលោភយ៉ាងធ្ងន់ធ្ងរលើសិទ្ធិមនុស្សនៅកម្ពុជា ភាគីក្នុងកិច្ចព្រមព្រៀងត្រូវស្នើដល់អង្គការមានសមត្ថកិច្ចរបស់អង្គការសហប្រជាជាតិ អោយចាត់វិធានការដទៃទៀតដែលសមស្រប ដើម្បីទប់ស្កាត់និងលុបបំបាត់ការរំលោភបែបនេះដោយស្របតាមច្បាប់អន្តរជាតិដែលទាក់ទិន ។

## មាត្រា ៦

កិច្ចព្រមព្រៀងនេះនឹងចូលជាធរមាននៅពេលចុះហត្ថលេខា ។

## មាត្រា ៧

កិច្ចព្រមព្រៀងនេះត្រូវទុកចំហសំរាប់រដ្ឋទាំងអស់ចូលរួម ។ ពាក្យសុំចូលជាភាគី ត្រូវតំកល់ទុកនៅនឹងរដ្ឋាភិបាលសាធារណរដ្ឋបារាំង និងសាធារណរដ្ឋឥណ្ឌូនេស៊ី ។ សំរាប់រដ្ឋនីមួយៗដែលចូលរួមក្នុងកិច្ចព្រមព្រៀងនេះ ពាក្យសុំចូលនោះត្រូវចូលជាធរមាននៅថ្ងៃតំកល់ទុកពាក្យសុំចូលរួម របស់ខ្លួន ។

## មាត្រា ៨

ច្បាប់ដើមនៃកិច្ចព្រមព្រៀងនេះ ដែលមានជាភាសាចិន - អង់គ្លេស - បារាំង - ខ្មែរ និងរុស្ស៊ី មានតំលៃដូចគ្នា ត្រូវដាក់តំកល់ទុកនៅរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំងនិងសាធារណរដ្ឋឥណ្ឌូនេស៊ី ដែលនឹងបញ្ជូនច្បាប់ចំលងដែលបានបញ្ជាក់ត្រឹមត្រូវហើយ ទៅរដ្ឋាភិបាលនៃរដ្ឋដទៃៗ ដែលចូលរួមក្នុងសន្និសីទប៉ារីសស្តីពីកម្ពុជា និងជូនលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

ដើម្បីជាសក្ខីភាព បណ្ដាប្រតិភូពេញសមត្ថកិច្ច ដូចមានរាយនាមខាងក្រោមដែលទទួលសិទ្ធិត្រឹមត្រូវហើយនោះ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ។

ធ្វើនៅក្រុងប៉ារីស ថ្ងៃទី ២៣ ខែតុលា ១៩៩១

# III- សេចក្តីថ្លែងការណ៍ស្តីពីការស្តារ និងការកសាងប្រទេសកម្ពុជាឡើងវិញ

១- ទិសដៅជាមូលដ្ឋាននៃការកសាងប្រទេសកម្ពុជាឡើងវិញ គឺការរីកចំរើននៃប្រជាជាតិ និងប្រជាជនកម្ពុជា ដោយគ្មានការប្រកាន់រើសអើង ឬការធ្វើអោយខូចប្រយោជន៍ ហើយដោយគោរពយ៉ាងពេញលេញដល់សិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានសំរាប់ជនគ្រប់រូប ។ ដើម្បីសំរេចអោយបាននូវគោលដៅនេះ គឺត្រូវទាមទារការអនុវត្តន៍ពេញលេញនូវដំណោះស្រាយនយោបាយរួមមួយ ។

២- ការទទួលខុសត្រូវជាសំខាន់ ក្នុងការសំរេចអំពីសេចក្តីត្រូវការ និងគំរោងផែនការទាំងឡាយសំរាប់ការកសាងប្រទេសកម្ពុជាឡើងវិញ ត្រូវស្ថិតនៅលើប្រជាជន និងរដ្ឋាភិបាលកម្ពុជាដែលត្រូវបង្កើតឡើងតាមរយៈការបោះឆ្នោតដោយសេរី និងត្រឹមត្រូវ ។ មិនត្រូវមានការប៉ុនប៉ងពី សំណាក់ប្រភពខាងក្រៅណាមួយ ដើម្បីបង្ខិតបង្ខំអោយប្រទេសកម្ពុជាទទួលយកនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍មួយ ឬរបស់ទាយក - អ្នកផ្តល់អំណោយ - ទាំងឡាយក្នុងការចូលរួមចំណែកដល់ការកសាងប្រទេសកម្ពុជាឡើងវិញនោះឡើយ ។

៣- ជំនួយឧបត្ថម្ភជាលក្ខណៈអន្តរជាតិ ជាលក្ខណៈតំបន់និងជាលក្ខណៈទ្វេភាគីដល់ប្រទេសកម្ពុជា គប្បីត្រូវបានសំរបសំរួលជាអតិបរមាតាមការដែលអាចធ្វើទៅបាន ដើម្បីបំពេញបន្ថែមទៅលើធនធានក្នុងប្រទេស ហើយនិងត្រូវបានផ្តល់អោយដោយឥតលំអៀង និង ដោយគិតគូរយ៉ាងពេញលេញដល់អធិបតេយ្យភាព អាទិភាព មធ្យោបាយទាំងឡាយនៃស្ថាប័ននានា ហើយនិងសមត្ថភាពស្រូបយកជំនួយរបស់ប្រទេសកម្ពុជា ។

៤- នៅក្នុងក្របខ័ណ្ឌនៃកិច្ចប្រឹងប្រែងកសាងប្រទេសឡើងវិញនេះ ជំនួយសេដ្ឋកិច្ចត្រូវតែបំរើផលប្រយោជន៍ដល់គ្រប់តំបន់នៃប្រទេសកម្ពុជា ជាពិសេសតំបន់ដែលចាញ់ប្រៀបជាងគេ ហើយត្រូវតែ បានទៅដល់គ្រប់ស្រទាប់នៃសង្គម ។

៥- ការអនុវត្តន៍នូវការខិតខំប្រឹងប្រែងផ្តល់ជំនួយជាអន្តរជាតិ ត្រូវធ្វើឡើងជាកំណាត់ៗនៅក្នុងរយៈពេលមួយ ដែលទទួលស្គាល់ដោយជាក់ស្តែងនូវភាពចាំបាច់ខាងនយោបាយ និងបច្ចេកទេស ។ ការអនុវត្តន៍នេះត្រូវតែអោយមានសហប្រតិបត្តិការដ៏សំខាន់មួយរវាងរដ្ឋាភិបាលកម្ពុជា និងអ្នកចូលរួមវិភាគទានជាទ្វេភាគីក្នុងតំបន់ និងអន្តរជាតិ ។

៦- ប្រព័ន្ធសហប្រជាជាតិត្រូវមានតួនាទីដ៏សំខាន់មួយ ក្នុងការស្តារនិងកសាងឡើងវិញ ។ ការចាប់ផ្តើមលើកផែនការកសាងឡើងវិញ និងការរំពាវនាវជាអន្តរជាតិដើម្បីវិភាគទាន ត្រូវប្រព្រឹត្តទៅនៅពេលដ៏សមស្រប ដើម្បីធានានូវជោគជ័យរបស់ខ្លួន ។

៧- គេមិនអាចផ្តួចផ្តើមកម្មវិធីមានប្រសិទ្ធភាព ស្តីពីការកសាងជាតិឡើងវិញបានទេ បើ គ្មានការវាយតំលៃលំអិតអំពីភោគទ្រព្យខាងកំលាំងមនុស្ស ខាងធម្មជាតិនិងខាងសេដ្ឋកិច្ចផ្សេងៗទៀតនោះ ។ ជាការចាំបាច់ត្រូវធ្វើបញ្ជីជំរឿនប្រជាជន

ពិនិត្យមើលលទ្ធភាពផ្នែកខាងការអភិវឌ្ឍន៍ និងការកំណត់អោយបានច្បាស់នូវធនធានដែលមាននៅក្នុងប្រទេស និងក្រៅប្រទេស ។

ដើម្បីសំរេចគោលបំណងនេះ ត្រូវមានចំរោងបញ្ជូនទៅកាន់កម្ពុជានូវបេសកកម្មស្វែងយល់ការពិតរបស់ប្រព័ន្ធអង្គការសហប្រជាជាតិ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងភ្នាក់ងារដទៃទៀត ដោយមានការយល់ព្រមពីរដ្ឋាភិបាលកម្ពុជាអនាគត ។

៨- អាស្រ័យដោយគេសំរេចបានដំណោះស្រាយនៃនយោបាយរួចនោះ នាពេលនេះ គេអាចធ្វើហើយគួរតែធ្វើនូវការផ្តួចផ្តើមដំណើរការស្តារឡើងវិញ សំដៅដោះស្រាយសេចក្តីត្រូវការជាបន្ទាន់ និងកសាងលក្ខណៈសម្បត្តិមូលដ្ឋានសំរាប់ការរៀបចំនូវផែនការកសាងឡើងវិញដែលមានរយៈពេលមធ្យម និងរយៈពេលវែង ។

៩- សំរាប់ដំណាក់កាលនៃការស្តារឡើងវិញនេះ គេស្នើអោយអគ្គលេខាធិការអង្គការសហប្រជាជាតិសំរបសំរួលកម្មវិធីដឹកនាំដោយមនុស្សម្នាក់ដែលត្រូវបានតែងតាំងឡើងសំរាប់គោលបំណងនេះ ។

១០- នៅក្នុងដំណាក់កាលស្តារឡើងវិញនេះ ត្រូវយកចិត្តទុកដាក់ជាពិសេសទៅលើការផ្គត់ផ្គង់ស្បៀង សុខភាព ទីលំនៅ ការហ្វឹកហ្វឺន ការអប់រំ ប្រព័ន្ធគមនាគមន៍ និងការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន និងសេវា សំភារៈប្រើប្រាស់ជាសាធារណៈដែលមានស្រាប់របស់កម្ពុជា ។

១១- ការអនុវត្តន៍ផែនការអភិវឌ្ឍន៍ជាតិសំរាប់រយៈពេលវែងស្តីពីការកសាងឡើងវិញត្រូវរង់ចាំដល់ការបង្កើតរដ្ឋាភិបាលមួយ បន្ទាប់ពីការបោះឆ្នោត និងការសំរេចចិត្តនិងការអនុម័តនូវគោលនយោបាយនិងអាទិភាពផ្ទាល់របស់ខ្លួន ។

១២- ដំណាក់កាលនៃការកសាងឡើងវិញនេះ ត្រូវជំរុញលើកកំពស់ស្មារតីសហគ្រិនសហគ្រាសរបស់កម្ពុជា ហើយប្រើប្រាស់វិស័យឯកជនក្នុងចំណោមវិស័យនានាជាច្រើនទៀត ដើម្បីជួយជំរុញការរីកចំរើនសេដ្ឋកិច្ចដោយខ្លួនឯងផ្ទាល់ ។ ដំណាក់កាលនេះក៏ត្រូវទទួលផលប្រយោជន៍ពីតំបន់ផងដែរ ដែលក្នុងនោះមានការពាក់ព័ន្ធដល់ស្ថាប័ននានាដូចជា គណៈកម្មការសេដ្ឋកិច្ច - សង្គមកិច្ច សំរាប់អាស៊ីប៉ាស៊ីហ្វិក "ESCAP" និងគណៈកម្មាធិការទន្លេមេគង្គជាដើម ហើយពីបណ្តារដ្ឋាភិបាលនៅក្នុងតំបន់ និងពីការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាល ។

១៣- ដើម្បីបានស៊ីចង្វាក់គ្នា និងតាមដានការចូលភាគទានដែលត្រូវផ្តល់អោយដោយសហគមន៍អន្តរជាតិសំរាប់ការកសាងប្រទេសកម្ពុជាឡើងវិញក្រោយការបង្កើតរដ្ឋាភិបាលមួយបន្ទាប់ពីការបោះឆ្នោត គេត្រូវបង្កើតស្ថាប័នពិគ្រោះយោបល់មួយហៅថា គណៈកម្មាធិការអន្តរជាតិ ស្តីពីការកសាងប្រទេសកម្ពុជាឡើងវិញ " ICORC " នៅពេលវេលាមួយសមស្រប និងបើកចំហចំពោះអ្នកធ្វើអំណោយនិងភាគីទាំងឡាយដែលទាក់ទិន ។ គេស្នើលោកអគ្គលេខាធិការនៃអង្គការសហប្រជាជាតិអោយធ្វើការរៀបចំពិសេសសំរាប់អោយប្រព័ន្ធអង្គការសហប្រជាជាតិ គាំទ្រគណៈកម្មាធិការអន្តរជាតិស្តីពីការកសាងប្រទេសកម្ពុជាឡើងវិញ " ICORC " ក្នុងការធ្វើការងាររបស់ខ្លួន ដូចជាធ្វើអោយមានការផ្លាស់ប្តូរដោយគ្មានការរអាក់រអួលពីដំណាក់កាលស្តារឡើងវិញ ទៅដំណាក់កាលកសាងឡើងវិញ ។

# កិច្ចព្រមព្រៀងចុងក្រោយនៃសន្និសីទ

# ប៉ារីស៍ស្តីពីកម្ពុជា

១- សន្និសីទទីក្រុងប៉ារីស៍ស្តីពីកម្ពុជា ត្រូវបានកោះប្រជុំតាមការអញ្ជើញរបស់រដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង ក្នុងទិសដៅឈានទៅដល់ដំណោះស្រាយរួមមួយ ដោយមានការធានាជាអន្តរជាតិ ដែលនឹងនាំសន្តិភាពមកអោយប្រទេសដែលបានឆ្លងកាត់ជម្លោះប្រកបដោយសោកនាដកម្ម និងការបង្ហូរឈាមនេះ ។

សន្និសីទបានប្រព្រឹត្តទៅដោយមានសម័យប្រជុំពីរលើក លើកទីមួយ ពីថ្ងៃទី ៣០ ខែកក្កដា ដល់ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៨៩ ហើយលើកទីពីរ ពីថ្ងៃទី ២១ ដល់ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ១៩៩១ ។

២- សហប្រធាននៃសន្និសីទ មាន ៖

ឯកឧត្តម រ៉ូឡង់ ឌុយម៉ាស៍ រដ្ឋមន្ត្រីក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង និង ឯកឧត្តម អាលីអាឡាតាស រដ្ឋមន្ត្រី ក្រសួងការបរទេសនៃសាធារណរដ្ឋឥណ្ឌូណេស៊ី ។

៣- រដ្ឋដែលបានចូលរួមក្នុងសន្និសីទ មានដូចតទៅ ៖

អូស្ត្រាលី ប្រ៊ុយណេដារុស្សាឡាំ កម្ពុជា កាណាដា សាធារណរដ្ឋប្រជាមានិតចិន សហរដ្ឋអាមេរិក សាធារណរដ្ឋបារាំង សាធារណរដ្ឋឥណ្ឌា សាធារណរដ្ឋឥណ្ឌូណេស៊ី ជប៉ុន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ម៉ាឡេស៊ី សាធារណរដ្ឋហ្វីលីពីន ព្រះរាជាណាចក្ររួមអង់គ្លេសនិងអៀរឡង់ខាងជើង សាធារណរដ្ឋសិង្ហបុរី រាជាណាចក្រថៃឡង់ សហភាពសាធារណរដ្ឋសង្គមនិយមសូវៀត សាធារណរដ្ឋសង្គមនិយមវៀតណាម ។

បន្ថែមពីលើនេះ ចលនាមិនចូលបក្សសម្ព័ន្ធត្រូវបានតំណាងដោយរដ្ឋដែលធ្វើជាប្រធានចលនានោះ ចំពោះពេលដែលសន្និសីទប្រជុំម្តងៗ នោះគឺហ្ស៊ីមបាវេ នៅសម័យប្រជុំលើកទីមួយ និង យូហ្គោស្លាវី នៅសម័យប្រជុំលើកទីពីរ ។

៤- ក្នុងឱកាសសម័យប្រជុំលើកទីមួយនៃសន្និសីទ ប្រទេសកម្ពុជាត្រូវបានតំណាងដោយភាគីកម្ពុជាទាំងបួន ។ ក្នុងឱកាសសម័យប្រជុំលើកទីពីរនៃសន្និសីទ ប្រទេសកម្ពុជាត្រូវបានតំណាងដោយក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ក្រោមអធិបតីភាពនៃប្រធានរបស់ខ្លួន គឺសម្តេច នរោត្តម សីហនុ ។

៨- អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ឯកឧត្តម ហាវីយេរ ប៉េរ៉េស ដេគូអេយ៉ា និង តំណាងពិសេសរបស់ លោក គឺលោក រ៉ាហ្វីអ៊ីន អាហ៍ម៉េដ ក៏បានចូលរួមក្នុងសន្និសីទនោះដែរ ។

៩- សន្និសីទបានរៀបចំការងាររបស់ខ្លួនដោយបង្កើតនូវគណៈកម្មការការងារធំៗបី ដែលអ្នកចូលរួមទាំងអស់ មានតំណាងរបស់ខ្លួននៅក្នុងគណៈកម្មការទាំងនោះ ហើយដែលបានប្រជុំគ្នាក្នុងរយៈពេលនៃសម័យប្រជុំលើកទីមួយរបស់ សន្និសីទ ។ គណៈកម្មការទីមួយបានពិភាក្សាលើបញ្ហាយោធា គណៈកម្មការទីពីរបានពិភាក្សាលើការធានាអន្តរជាតិ គណៈ កម្មការទីបីបានពិភាក្សាលើបញ្ហាមាតុភូមិនិវត្តន៍នៃជនភៀសខ្លួន [illegible] និងការកសាងប្រទេសកម្ពុជាឡើងវិញ ។

បណ្ដាប្រធាន និងអ្នករាយការណ៍របស់គណៈកម្មការនីមួយៗ មាន :

<u>ចំពោះគណៈកម្មការទីមួយ</u> :

<u>សហប្រធាន</u> : លោក ស.រ. ហ្គាប់ខាន់ (ឥណ្ឌា)

លោក អាឡង់ ស៊ូលើវ៉ង់ (កាណាដា)

<u>អ្នករាយការណ៍</u> : លោកស្រី វិគ្គរីយ៉ា ស៊ុសង់ខេ បាចាកូង់ (ហ្វីលីពីន)

<u>ចំពោះគណៈកម្មការទីពីរ</u> :

<u>សហប្រធាន</u> : លោក ស៊ុលើវង្ស ប្រាស៊ុធីដេជ (ឡាវ)

លោក ហ្សាឈែរ៍ អាប៊ីឌីន អ៊ុប្រាហ៊ីម (ម៉ាឡេស៊ី)

<u>អ្នករាយការណ៍</u> : លោក ម៉ែរប៉ឺ ដិហ្សង់ ជិឡាបាទី (បារាំង)

<u>ចំពោះគណៈកម្មការទីបី</u> :

<u>សហប្រធាន</u> : លោក យូស៊ិដ្ឋិ អ៊ីម៉ាហ្គាំ (ជប៉ុន)

លោក រ៉ូប៊ែរ៍ ម៉េរ៉ែហ្វូស (អូស្ត្រាលី)

<u>អ្នករាយការណ៍</u> : វរសេនីយ៍ឯក រ៉ូណាដុក ស្វាអេខិបាច (ថៃឡង់)

សន្និសីទក៏បានបង្កើតផងដែរនូវគណៈកម្មាធិការ ចំពោះកិច្ច (ad hoc) ដែលមានតំណាងរបស់ភាគីកម្ពុជាទាំងបួនជា សមាជិក និងដឹកនាំដោយតំណាងរបស់សហប្រធានទាំងពីរនៃសន្និសីទ ។ ភារកិច្ចនៃគណៈកម្មាធិការនេះ គឺទទួលបន្ទុកបញ្ហា ដែលទាក់ទងដល់ការបង្រួបបង្រួមជាតិរវាងបណ្ដាភាគីកម្ពុជា ។ គណៈកម្មាធិការចំពោះកិច្ចនេះបានធ្វើការប្រជុំជាច្រើនលើក នៅក្នុងរយៈពេលនៃសម័យប្រជុំលើកទីមួយរបស់សន្និសីទ ។

គណៈកម្មាធិការសំរបសំរួលនៃសន្និសីទ ដឹកនាំដោយតំណាងរបស់សហប្រធានទាំងពីរ ត្រូវបានបង្កើតឡើង ហើយភារកិច្ចទូលំទូលាយស្រាវជ្រាវការសំរបសំរួលជាទូទៅចំពោះការងាររបស់គណៈកម្មការទាំងបួនផ្សេងទៀត ត្រូវបានប្រគល់អោយគណៈកម្មាធិការនេះ ។

គណៈកម្មាធិការសំរបសំរួលបានធ្វើការប្រជុំរវាងពេលសម័យប្រជុំទី១និងទី២របស់សន្និសីទ ។ ការប្រជុំក្រៅផ្លូវការមួយរបស់គណៈកម្មាធិការសំរបសំរួល ក៏បានប្រព្រឹត្តទៅនៅទីក្រុង ញូវយ៉ក កាលពីថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ១៩៨៩ ក្នុងពេលនោះផងដែរ ។

៧- នៅទីបញ្ចប់នៃសម័យប្រជុំលើកទីមួយ សន្និសីទបានជឿនលឿនទៅមុខក្នុងការរៀបចំផ្លូវដំណោះស្រាយជាច្រើន និងចាំបាច់ដើម្បីឈានទៅដល់ដំណោះស្រាយរួមមួយនៃជម្លោះកម្ពុជា ។ ក៏ប៉ុន្តែសន្និសីទបានកត់សំគាល់ថា នៅពុំទាន់មានលទ្ធភាពឈានទៅដល់ដំណោះស្រាយរួមនៅឡើយទេ ។

ហេតុដូច្នេះមានការសំរេចថា ផ្អាកសន្និសីទនៅថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៨៩ សិន ។ ជាមួយគ្នានោះ សន្និសីទបានអំពាវនាវដល់ភាគីជាប់ទាក់ទិនទាំងអស់ អោយបង្កើនការខិតខំដើម្បីឈានទៅដល់ដំណោះស្រាយរួម និងបានស្នើដល់សហប្រធានអោយជួយឧបត្ថម្ភគ្រប់គ្រងសំរួលដល់ការខិតខំទាំងនោះ ។

៨- បន្ទាប់ពីការផ្អាកសម័យប្រជុំលើកទីមួយនៃសន្និសីទមក សហប្រធាននិងអគ្គលេខាធិការអង្គការសហប្រជាជាតិ បានធ្វើការពិគ្រោះយ៉ាងទូលំទូលាយ ជាពិសេសជាមួយសមាជិកអចិន្ត្រៃយ៍ទាំង ៥ របស់ក្រុមប្រឹក្សាសន្តិសុខសហប្រជាជាតិ ជាមួយក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជា និងជាមួយអ្នកចូលរួមដទៃទៀតនៃសន្និសីទប៉ារីស ។

កម្មវត្ថុនៃការពិគ្រោះទាំងនោះ គឺការរៀបចំកិច្ចព្រមព្រៀងមួយស្តីអំពីទិដ្ឋភាពទាំងអស់នៃដំណោះស្រាយ ការធានានូវទំនាក់ទំនងនៃធាតុផ្សំទាំងអស់ដែលត្រូវបានអនុម័តក្នុងពេលចំពោះនោះ និងការបង្កើតឲ្យមានស្ថានការ បញ្ចប់ការបង្ហូរឈាមនៅកម្ពុជា អោយបានឆាប់ជាទីបំផុត ។ ការប្រឹងប្រែងរបស់សហប្រធាន និងអគ្គលេខាធិការបានអនុញ្ញាតអោយកោះប្រជុំជាថ្មីនូវសន្និសីទទីក្រុងប៉ារីសស្តីពីកម្ពុជា ។

៩- នៅក្នុងដំណាក់កាលបើកសម័យប្រជុំបញ្ចប់នៃសន្និសីទប៉ារីសថ្ងៃ ២៣ តុលា ១៩៩១ ឯកឧត្តម ហ្វ្រង់ស្វា មិតេរ៉ង់ ប្រធានាធិបតីនៃសាធារណរដ្ឋបារាំង សម្តេច នរោត្តម សីហនុ ប្រធានក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជា និង ឯកឧត្តម ហាវីយ៉េរ ប៉េរេស ដេគូអេយ៉ារ អគ្គលេខាធិការអង្គការសហប្រជាជាតិ បានមានសុន្ទរកថាចំពោះអង្គសន្និសីទ ។

១០. នៅក្នុងសម័យប្រជុំលើកទីពីរសន្និសីទបានអនុម័តនូវឯកសារដូចខាងក្រោម ៖

១. កិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជា ដោយមានភ្ជាប់នូវឧបសម្ព័ន្ធស្តីពីអាណត្តិរបស់អាជ្ញាធរបណ្តោះអាសន្ន អ.ស.ប. នៅកម្ពុជា បញ្ហាយោធា ការបោះឆ្នោត មាតុភូមិនិវត្តន៍នៃជនភៀសខ្លួនកម្ពុជា និងជនផ្លាស់ប្តូរទីកន្លែង និងរដ្ឋធម្មនុញ្ញថ្មីរបស់កម្ពុជា ។

២. កិច្ចព្រមព្រៀងស្តីពីអធិបតេយ្យភាព ឯករាជ្យ បូរណភាព និងភាពមិនអាចរំលោភបាននៃទឹកដី អព្យាក្រឹតភាព និង ឯកភាពជាតិរបស់កម្ពុជា និង

៣. សេចក្តីថ្លែងការណ៍ស្តីពីការស្តារនិងការកសាងប្រទេសកម្ពុជាឡើងវិញ ។

ឯកសារទាំងនេះត្រូវបានរៀបរៀងឡើងលើមូលដ្ឋាននៃ ៖ ឯកសារ ក្របខ័ណ្ឌដើម្បីដំណោះស្រាយនយោបាយរួមនៃជម្លោះកម្ពុជា ៖ ដែលត្រូវបានអនុម័តដោយសមាជិកអចិន្ត្រៃយ៍ទាំងប្រាំនៃក្រុមប្រឹក្សាសន្តិសុខសហប្រជាជាតិកាលពីថ្ងៃទី ២៨ ខែ សីហា ១៩៩០ និងឯកសារការងារដែលត្រូវបានរៀបចំឡើងនាសម័យប្រជុំលើកទីមួយរបស់សន្និសីទ ។ ឯកសារទាំងនេះគ្រោងនូវដំណើរការបន្តបន្ទាប់មួយនៃការបង្រួបបង្រួមជាតិ ព្រមទាំងនូវ[illegible] របស់សហប្រជាជាតិ ដែលអនុញ្ញាតអោយប្រជាជនកម្ពុជាកំណត់យកអនាគតនយោបាយរបស់ខ្លួន តាមរយៈការបោះឆ្នោតដោយសេរីនិងត្រឹមត្រូវ រៀបចំនិងដឹកនាំដោយសហប្រជាជាតិនៅក្នុងបរិយាកាសនយោបាយអព្យាក្រឹតមួយ និងដោយមានការគោរពពេញទីចំពោះអធិបតេយ្យភាពជាតិរបស់កម្ពុជា ។

១១- ឯកសារទាំងនេះ ដែលរួមផ្សំគ្នាទាំងដំណោះស្រាយរួម ដែលជាគោលដៅរបស់សន្និសីទប៉ារីសនោះ ត្រូវបានបើកឡើងដើម្បីអោយបណ្តារដ្ឋចូលរួមសន្និសីទប៉ារីសចុះហត្ថលេខា ។ ចំពោះប្រទេសកម្ពុជា ឯកសារទាំងនេះនឹងត្រូវបានចុះហត្ថលេខាដោយសមាជិកទាំង ១២ នៃក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជា ដែលជាអង្គការស្របច្បាប់ និងជាប្រភពនៃអំណាចដ៏តំណាងអោយអធិបតេយ្យភាព ឯករាជ្យ និងឯកភាពជាតិរបស់កម្ពុជា ។

១២ បណ្តារដ្ឋចូលរួមក្នុងសន្និសីទស្នើសុំអោយសហប្រធាននៃសន្និសីទបញ្ជូននូវច្បាប់ត្រឹមត្រូវមួយច្បាប់នៃឯកសារស្តីពីដំណោះស្រាយនយោបាយរួមនេះ ជូនលោកអគ្គលេខាធិការ អ.ស.ប. ។ បណ្តារដ្ឋចូលរួមសន្និសីទស្នើដល់លោកអគ្គលេខាធិការអោយប្រកាន់យកនូវវិធានការសមស្រប អោយដំណោះស្រាយរួមនេះត្រូវបានក្រុមប្រឹក្សាសន្តិសុខសហ-

ប្រជាជាតិពិនិត្យយ៉ាងជាប់ចំផុត ។ បណ្តារដ្ឋទាំងនេះសន្យាថា និងសហការយ៉ាងពេញទំហឹងដើម្បីអោយដំណោះស្រាយនេះ ត្រូវបានសំរេច ហើយនឹងជួយនៅក្នុងការអនុវត្តដំណោះស្រាយនេះ ។

ជាពិសេស ដោយមើលឃើញនូវប្រវត្តិសាស្ត្រថ្មីៗ ប្រកបដោយសោកនាដកម្ម នៃប្រទេសកម្ពុជា បណ្តារដ្ឋ ចូលរួមក្នុងសន្និសីទ បានសន្យាជំរុញ និងលើកទឹកចិត្តអោយមានការគោរព និង ប្រតិបត្តិតាមសិទ្ធិមនុស្ស និង សេរីភាពជាមូលដ្ឋាន នៅក្នុងប្រទេសកម្ពុជា ដូចមានចែងនៅក្នុងបណ្តាកិច្ចព្រមព្រៀងអន្តរជាតិ ដែលមាក់ទងដល់បញ្ហានេះ ហើយដែលណ្តារដ្ឋនោះ ជាភាគីចូល រួមផងដែរ ។

១៣ - បណ្តារដ្ឋចូលរួមក្នុងសន្និសីទ ស្នើអោយគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិជួយសំរួលការដោះលែង ឈ្លើយសឹក និងអ្នកជាប់ឃុំឃាំងស៊ីវិល ស្របតាមគោលការណ៍របស់ខ្លួន ។ បណ្តារដ្ឋទាំងនេះ ត្រៀមនឹងជួយដល់គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិនៅក្នុងភារកិច្ចនេះ ។

១៤ - បណ្តារដ្ឋចូលរួមក្នុងសន្និសីទ សូមអញ្ជើញដល់បណ្តារដ្ឋផ្សេងទៀត អោយចូលរួមក្នុងកិច្ចព្រមព្រៀង ស្តីពីដំណោះស្រាយនយោបាយរួមមួយ នៃជម្លោះកម្ពុជា និង ក្នុងកិច្ចព្រមព្រៀង ស្តីពីអធិបតេយ្យភាព ឯករាជ្យ បូរណភាព និងភាពមិនរំលោភបាន នៃដែនដី អព្យាក្រឹតភាព និង ឯកភាពជាតិរបស់កម្ពុជា ។

១៥ ដោយពិនិត្យឃើញនូវសេចក្តីត្រូវការអោយមានការខិតខំប្រឹងប្រែងជាអន្តរជាតិដោយស៊ីសង្វាក់គ្នា ដើម្បីជួយដល់ការស្តារនិងការកសាងប្រទេសកម្ពុជាឡើងវិញ បណ្តារដ្ឋចូលរួមសន្និសីទអំពាវនាវដោយទទូចដល់សហគមន៍អន្តរជាតិ អោយផ្តល់នូវការគាំទ្រជាសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដោយសប្បុរស ស្របតាមវិធានការដែលត្រូវបានលើកឡើងនៅក្នុងសេចក្តីថ្លែងការណ៍ស្តីអំពីការស្តារ និងការកសាងប្រទេសកម្ពុជាឡើងវិញ ។

ដើម្បីជាសំអាង បណ្តាតំណាងបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងបញ្ចប់នេះ ។

ធ្វើនៅទីក្រុងប៉ារីស៍ ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ១៩៩១ ជាពីរច្បាប់ ជាភាសាអង់គ្លេស បារាំង ខ្មែរ និង រុស្ស៊ី ដោយច្បាប់ជាភាសានីមួយៗមានតម្លៃដូចគ្នា ។ ច្បាប់ដើមនៃកិច្ចព្រមព្រៀងបញ្ចប់នេះនឹងត្រូវតម្កល់ទុកនៅនឹងរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង និងសាធារណរដ្ឋឥណ្ឌូនេស៊ី ។

For the Government of the Republic of Indonesia,

印度尼西亚共和国政府：

Pour le Gouvernement de la République d'Indonésie,

ជ. រដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌូនេស៊ី

За Правительство Республики Индонезия

For the Government of the French Republic,

法兰西共和国政府：

Pour le Gouvernement de la République Française,

ជ. រដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង

За Правительство Французской Республики

For the Supreme National Council of Cambodia:

柬埔寨全国最高委员会：

Pour le Conseil National Suprême du Cambodge,

ជ.ក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជា

За Высший Национальный Совет Камбоджи

S.A.R. Le Prince NORODOM SIHANOUK, Président du Conseil National Suprême,

M. DITH MUNTY

M. HOR NAM HONG

M. HUN SEN

M. IENG MOULY

M. IM CHHUN LIM

M. KHIEU SAMPHAN

S. A. R. Le Prince NORODOM RANARIDDH

M. SIN SEN

M. SON SANN

M. SON SEN

M. TEA BANH

澳大利亚政府：

Pour le Gouvernement de l'Australie,

ជ. រដ្ឋាភិបាលអូស្ត្រាលី

За Правительство Австралии

For the Government of Brunei Darussalam,

文莱达鲁萨兰国政府：

Pour le Gouvernement de Brunei Darussalam,

ជ. រដ្ឋាភិបាលប្រ៊ុយណេដារូសាឡាម

За Правительство Брунея-Даруссалама

For the Government of Canada,

加拿大政府：

Pour le Gouvernement du Canada,

ជ. រដ្ឋាភិបាលកាណាដា

За Правительство Канады

For the Government of the People's Republic of China,

中华人民共和国政府：

Pour le Gouvernement de la République populaire de Chine,

ជ. រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន

За Правительство Китайской Народной Республики



For the Government of the United States of America,

美利坚合众国政府：

Pour le Gouvernement des Etats Unis d'Amérique,

ជ. រដ្ឋាភិបាលនៃសហរដ្ឋអាមេរិក

За Правительство Соединенных Штатов Америки



For the Government of the Republic of India,

印度共和国政府：

Pour le Gouvernement de la République de l'Inde,

ជ. រដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌា

За Правительство Республики Индия



For the Government of Japan,

日本国政府：

Pour le Gouvernement du Japon,

[illegible]

За Правительство Японии

For the Government of the Lao People's Democratic Republic,

老挝人民民主共和国政府：

Pour le Gouvernement de la République Démocratique Populaire Lao,

[illegible]

За Правительство Лаосской Народно-Демократической Республики

For the Government of Malaysia,

马来西亚政府：

Pour le Gouvernement de la Malaisie,

[illegible]

За Правительство Малайзии

For the Government of the Republic of the Philippines,

菲律宾共和国政府：

Pour le Gouvernement de la République des Philippines,

ສ. ຣັຖາພິບານແຫ່ງສາທາຣະນະຣັຖຟີລິບປິນ

За Правительство Республики Филиппины

For the Government of the United Kingdom of Great Britain and Northern Ireland,

大不列颠及北爱尔兰联合王国政府：

Pour le Gouvernement du Royaume-Uni de Grande-Bretagne et d'Irlande du Nord,

ສ. ຣັຖາພິບານແຫ່ງສະຫະຣາຊະອານາຈັກບຣິເທນໃຫຍ່ ແລະ ໄອແລນເໜືອ

За Правительство Соединенного Королевства Великобритании и Северной Ирландии

For the Government of the Republic of Singapore,

新加坡共和国政府：

Pour le Gouvernement de la République de Singapour,

ສ. ຣັຖາພິບານແຫ່ງສາທາຣະນະຣັຖສິງຄະປູຣ໌

За Правительство Республики Сингапур

泰王国政府：

Pour le Gouvernement du Royaume de Thaïlande,

ជ. រដ្ឋាភិបាលនៃរាជាណាចក្រថៃ

За Правительство Королевства Таиланд

For the Government of the Union of Soviet Socialist Republics,

苏维埃社会主义共和国联盟政府：

Pour le Gouvernement de l'Union des Républiques Socialistes Soviétiques,

ជ. រដ្ឋាភិបាលនៃសហភាពសាធារណរដ្ឋសង្គមនិយមសូវៀត

За Правительство Союза Советских Социалистических Республик

For the Government of the Socialist Republic of Vietnam,

越南社会主义共和国政府：

Pour le Gouvernement de la République Socialiste du Vietnam,

ជ. រដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម

За Правительство Социалистической Республики Вьетнам

For the Government of the Federal Socialist Republic of Yugoslavia,

南斯拉夫社会主义联邦共和国：

Pour le Gouvernement de la République Socialiste Fédérative de Yougoslavie,

ជ. រដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមសហព័ន្ធយូហ្គោស្លាវី

За Правительство Социалистической Федеративной Республики Югослав

The Secretary-General of the United Nations,

联合国秘书长：

Le Secrétaire Général des Nations Unies,

អគ្គលេខាធិការសហប្រជាជាតិ

Генеральный Секретарь Организации Объединенных Наций